World Vision

# ដើម្បីជីវិតប្រសើរឡើងសម្រាប់កុមារ

## របាយការណ៍រីកចម្រើនប្រចាំឆ្នាំ ២០១១

អង្គការទស្សនៈពិភពលោកកម្ពុជា



# មាតិកា


៦ សាររបស់នាយិកា
៧ សេចក្តីសង្ខេបពីកម្មវិធីរបស់អង្គការទស្សនៈពិភពលោកកម្ពុជា
៨ ការបំផុសចលនាសហគមន៍
១០ សុខភាព អាហារូបត្ថម្ភ អេដស៍ និងអនាម័យទឹកស្អាត
១២ ការអប់រំ
១៤ ការការពារកុមារ
១៦ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងកសិកម្ម
១៨ ការតស៊ូមតិ
២០ ព័ន្ធកិច្ចគ្រិស្តបរិស័ទ
២២ កិច្ចការងារមនុស្សធម៌ និងជំនួយសង្គ្រោះបន្ទាន់
២៤ វីសិនហ្វាន់
២៦ របាយការណ៍ហិរញ្ញវត្ថុ




# ទស្សនវិស័យរបស់យើង
គឺចង់ឃើញកុមារគ្រប់រូបមានជីវិតពេញបរិបូរណ៍

# សេចក្តីអធិស្ឋានរបស់យើង
សូមឲ្យទឹកចិត្តមនុស្សគ្រប់រូបមានឆន្ទៈដើម្បីសម្រេចបំណងនេះ

## តើយើងជានរណា

អង្គការទស្សនៈពិភពលោក គឺជាអង្គការគ្រិស្តបរិស័ទ  ជំនួយសង្គ្រោះបន្ទាន់ អភិវឌ្ឍន៍ និងតស៊ូមតិ ប្តេជ្ញាធ្វើការបម្រើកុមារ គ្រួសារ និងសហគមន៍ ដើម្បីជំនះលើភាពក្រីក្រ និងភាពអយុត្តិធម៌។

## តើយើងធ្វើអ្វីខ្លះ

តាមរយៈការជំរុញទឹកចិត្តដោយជំនឿរបស់គ្រិស្តបរិស័ទ អង្គការទស្សនៈពិភពលោក បម្រើប្រជាពលរដ្ឋគ្រប់រូប មិនប្រកាន់សាសនា ពូជសាសន៍ ជនជាតិ ឬភេទឡើយ។

# តម្លៃជាមូលដ្ឋាន

### យើងជាគ្រិស្តបរិស័ទ

យើងបានទទួលការត្រាស់ហៅឲ្យបម្រើអ្នកដទៃក្នុងភាពបរិបូរណ៍នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

### យើងគោរពតម្លៃមនុស្ស

យើងចាត់ទុកមនុស្សទាំងអស់ថា ត្រូវបានបង្កើតនិងស្រឡាញ់ដោយព្រះជាម្ចាស់ ដោយម្នាក់ៗមានលក្ខណៈពិសេសទទួលសេចក្តីថ្លៃថ្នូរ ការគោរព និងមានតម្លៃក្នុងខ្លួន។

### យើងជាអ្នកបម្រើដែលមានការទទួលខុសត្រូវខ្ពស់

យើងស្មោះត្រង់ចំពោះគោលបំណងនៃធនធានដែលយើងបានទទួល និងគ្រប់គ្រងធនធានទាំងនោះក្នុងរបៀបដែលនាំមកនូវផលប្រយោជន៍ជាអតិបរមាដល់ជនក្រីក្រ។



### យើងប្តេជ្ញាជួយដល់ជនក្រីក្រ

យើងបានត្រូវត្រាស់ហៅឲ្យសម្រាលតម្រូវការ និងទុក្ខវេទនា ភ្ជាប់ទំនាក់ទំនងរវាងអ្នកក្រ និងអ្នកមាន។

### យើងជាអ្នកឆ្លើយតប

យើងឆ្លើយតបចំពោះគ្រោះអាសន្នដែលគំរាមកំហែងដល់អាយុជីវិត ព្រមទាំងស្ថានភាពសេដ្ឋកិច្ចសង្គមស្មុគស្មាញដែលតម្រូវឲ្យមានការអភិវឌ្ឍន៍យូរអង្វែង។

### យើងជាដៃគូ

ក្នុងនាមជាសមាជិកនៃអង្គការទស្សនៈ-ពិភពលោកអន្តរជាតិ យើងព្រមទទួលយកកាតព្វកិច្ចដែលមានការចូលរួមគោលដៅរួម និងមានគណនេយ្យភាពទៅវិញទៅមក។


POPEYE COMIC

# ដើម្បីជីវិតប្រសើរឡើងសម្រាប់កុមារ



ជូនចំពោះ មិត្តភ័ក្ត្រ សហការី និងដៃគូការងារទាំងអស់

ខ្ញុំមានកិត្តិយស និងសប្បាយរីករាយដែលបានធ្វើបទបង្ហាញពីរបាយការណ៍ប្រចាំឆ្នាំ២០១១ របស់អង្គការទស្សនៈពិភពលោកកម្ពុជា។

នៅក្នុងទំព័រនីមួយៗនៃរបាយការណ៍នេះលោកអ្នកនឹងឃើញពីការគាំទ្រដ៏សប្បុរសដល់កុមារទំនុកបម្រុងរបស់យើង ពីសំណាក់សាជីវកម្ម រដ្ឋាភិបាល ម្ចាស់ជំនួយ បុគ្គលិក និងអ្នកស្ម័គ្រចិត្ត អង្គការ និងក្រុមជំនុំជាដៃគូ ដែលបានធ្វើឲ្យកុមារ និងសហគមន៍អាចកសាងប្រទេសកម្ពុជាដ៏ប្រសើរ។ ខ្ញុំសូមទទួលស្គាល់ដល់រាជរដ្ឋាភិបាលកម្ពុជាជាពិសេស។ ប្រសិនបើគ្មានការដឹកនាំ និងការសហការយ៉ាងជិតស្និទពីសំណាក់រាជរដ្ឋាភិបាលកម្ពុជានោះទេ យើងក៏មិនអាចទទួលបានការផ្លាស់ប្តូរជាវិជ្ជមានដែលយើងឃើញរាល់ថ្ងៃនេះនោះទេ ។

នៅក្នុងឆ្នាំ២០១១ អង្គការទស្សនៈពិភពលោកកម្ពុជា បានចាប់ផ្តើមធ្វើដំណើរការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំដែលផ្តោតលើការសម្រេចឲ្យបាននូវជីវិតប្រសើរឡើងសម្រាប់កុមារ តាមរយៈការបំផុសចលនាសហគមន៍ និងការផ្តល់សិទ្ធិអំណាចដល់កុមារ គ្រួសាររបស់ពួកគេ និងសហគមន៍នានា ជាមួយការផ្តោតសំខាន់ទៅលើសុខភាព និងអាហារូបត្ថម្ភ ការអប់រំ និងការការពារកុមារ។

បើទោះបីជាមានការប្រឈមជាមួយឧបសគ្គជាច្រើន និងភាពមិនប្រាកដប្រជាដូចជាការងើបឡើងដ៏យឺតយ៉ាវនូវសេដ្ឋកិច្ចសកលលោក ជម្លោះដ៏តានតឹងជាមួយប្រទេសជិតខាង ការគំរាមកំហែងពីគ្រោះធម្មជាតិ ការកើនឡើងហានិភ័យនៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកុមារ ខ្ញុំសូមចែកចាយថាថ្វីបើមានការប្រឈមដ៏ធំធេងយ៉ាងនេះក៏ដោយ ក៏បុគ្គលិកអង្គការទស្សនៈពិភពលោក និងសហគមន៍នានាដែលយើងបានធ្វើការបម្រើជូននៅតែមានភាពអង់អាចក្នុងការកំណត់នូវការប្តេជ្ញាចិត្តរបស់ពួកគេ ដើម្បីធ្វើការផ្លាស់ប្រែ និងបន្តធ្វើឲ្យជីវិតកុមារប្រសើរឡើងនៅកម្ពុជា។ វិសិនហ្វាន់បានបន្តកិច្ចការងារបម្រើដល់ជនក្រីក្រ និងបម្រើដោយមិនស្ទាក់ស្ទើរក្នុងការផ្តល់ប្រាក់កម្ចីធ្វើពាណិជ្ជកម្មខ្នាតតូចដល់ក្រុមគ្រួសារណាដែលត្រូវការប្រាក់កម្ចីនេះជាចាំបាច់។ ខ្ញុំពិតជាមានភាពកក់ក្តៅជាខ្លាំងចំពោះការប្តូរផ្តាច់ និងការខិតខំប្រឹងប្រែងមិនចេះហត់នឿយរបស់បុគ្គលិក និងសហគមន៍ដែលទទួលផលរបស់យើងទាំងអស់។

ថ្ងៃនេះខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ដែលបានអនុញ្ញាតឲ្យអង្គការទស្សនៈពិភពលោក និងក្រុមហ៊ុនវីសិនហ្វាន់មានឱកាស និងសមត្ថភាពដើម្បីរួមចំណែកក្នុងការធ្វើឲ្យប្រទេសកម្ពុជារីកចម្រើន ដែលកុមារគ្រប់រូបអាចរៀនអាន និងរៀនសរសេរ ធំចម្រើនលូតលាស់ល្អ សុខភាពល្អ និងរស់ក្នុងសហគមន៍ដែលចេះថែរក្សា និងការពារពួកគេ។

សូមចូលរួមអធិស្ឋាន និងធ្វើការងារជាមួយពួកយើងដើម្បីជីវិតប្រសើរឡើងសម្រាប់កុមារនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០១២។

អេស្ទើ ហាលីម
នាយិកាប្រចាំប្រទេស
អង្គការទស្សនៈពិភពលោកកម្ពុជា

# សេចក្តីសង្ខេបពីកម្មវិធីរបស់អង្គការទស្សនៈពិភពលោកកម្ពុជា

នៅចុងឆ្នាំ២០១១ អង្គការទស្សនៈពិភពលោកកម្ពុជាបានប្រតិបត្តិកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន៤០នៅក្នុង៩ខេត្ត និងរាជធានីភ្នំពេញ ដែលបម្រើដល់កុមារទំនុកបម្រុងជាង៦.៤០០០នាក់ ព្រមទាំងគ្រួសារ និងសហគមន៍របស់ពួកគេផងដែរ។




កម្មវិធីអភិវឌ្ឍន៍តំបន់ដែលទទួលមូលនិធិតាមរយៈកម្មវិធីទំនុកបម្រុងកុមារ កំពុងតែអនុវត្តនៅក្នុងភូមិ និងសហគមន៍ដែលមានទីតាំងភូមិសាស្ត្រនៅជិតគ្នាហើយនោះក៏ជាកន្លែងដែលអង្គការទស្សនៈពិភពលោកធ្វើការលើកស្ទួយជីវភាពរស់នៅរបស់កុមារ និងក្រុមគ្រួសាររបស់ពួកគេផងដែរ។ នៅឆ្នាំ២០១១ អង្គការទស្សនៈពិភពលោក បានបន្តដាក់ការផ្តោតមួយដែលមានបំណងប្រាថ្នាចង់ឃើញកុមារមានជីវិតប្រសើរឡើង គឺមានន័យថាកុមារគ្រប់រូបទទួលបានការអប់រំសម្រាប់ជីវិត មានសុខភាពល្អ ទទួលបាននូវបទពិសោធន៍នៃសេចក្តីស្រលាញ់ពីព្រះជាម្ចាស់ និងអ្នកជិតខាង ទទួលបាននូវការថែរក្សា និងការការពារ ហើយនិងការចូលរួមចំណែកក្នុងការសម្រេចចិត្តដែលមានផលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។

អង្គការទស្សនៈពិភពលោកក៏បានអនុវត្តគម្រោងនានាជាមួយនឹងមូលនិធិដែលមិនមែនតាមរយៈកម្មវិធីទំនុកបម្រុងផងដែរ គឺដើម្បីដោះស្រាយនូវបញ្ហាពិសេសៗដែលប៉ះពាល់ដល់កុមារ និងយុវជនងាយរងគ្រោះក្នុងប្រទេសកម្ពុជា មានដូចជាការជួញដូរមនុស្ស ការកេងប្រវ័ញ្ចលើកុមារ ពលកម្មកុមារ និងកុមាររស់នៅតាមផ្លូវ។

## គោលដៅជាយុទ្ធសាស្ត្រ ដើម្បីសម្រេចបាននូវ ជីវិតប្រសើរឡើង សម្រាប់កុមារ ២០១១-២០១៦

- បង្កើនចំនួនកុមារដែលមានការលូតលាស់មាំមួនល្អ
- បង្កើនចំនួនកុមារដែលទទួលបានការការពារពីការឆ្លងរោគ និងជំងឺផ្សេងៗ
- បង្កើនចំនួនកុមារដែលអាចអានអក្សរបាននៅអាយុ ១១ឆ្នាំ
- កុមារអភិវឌ្ឍបំនិនជីវិតផ្តល់ប្រយោជន៍ដល់ខ្លួនគេផ្ទាល់ និងទូទាំងសហគមន៍របស់គេដែរ
- កុមារទទួលបានការការពារពីការរំលោភបំពាន និងការកេងប្រវ័ញ្ចតាមរយៈការទប់ស្កាត់និងការការពារដ៏មានប្រសិទ្ធភាព ព្រមទាំងយន្តការស្តារឡើងវិញ
- កុមារទទួលបាននូវការថែបំប៉នទំនាក់ទំនងល្អជាមួយព្រះជាម្ចាស់ អ្នកជិតខាង និងអ្នកនៅជុំវិញខ្លួនរបស់ពួកគេ

ទិសដៅយុទ្ធសាស្ត្ររបស់អង្គការទស្សនៈពិភពលោក ពិតជាស្របទៅតាមយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ជាពិសេសយុទ្ធសាស្ត្រវិស័យអប់រំ និងវិស័យសុខាភិបាល។ យើងប្តេជ្ញាធ្វើការរួមគ្នាជាមួយក្រសួងនានាដូចជា ក្រសួងអប់រំ ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ពីថ្នាក់ជាតិរហូតដល់ថ្នាក់ភូមិ។

ដើម្បីសិក្សាបន្ថែមពីការងាររបស់អង្គការទស្សនៈពិភពលោកកម្ពុជា សូមចូលទៅទស្សនាគេហទំព័រ៖ **www.worldvision.org.kh**







# ការបំផុសចលនាសហគមន៍គឺដើម្បី ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

ការបំផុសចលនាសហគមន៍គឺកសាងមូលដ្ឋានគ្រឹះឲ្យសហគមន៍មានភាពជាម្ចាស់ និងចូលរួមធ្វើឲ្យមានស្ថិរភាពការអភិវឌ្ឍន៍យូរអង្វែង ដោយឲ្យសហគមន៍កាច់ចង្កូតនាវាអភិវឌ្ឍន៍នេះដោយខ្លួនឯង យើងអាចធានាបានថាសហគមន៍ប្តេជ្ញាចិត្តបោះជំហានឆ្ពោះទៅកាន់ដំណាក់កាលចាំបាច់នានា ដើម្បីធ្វើឲ្យជីវិតរបស់ពួកគេបានប្រសើរឡើង ជាពិសេសចំពោះជីវិតកុមារ។ អង្គការទស្សនៈពិភពលោកធ្វើការជាមួយកុមារ និងសហគមន៍ដើម្បីកសាងសមត្ថភាពរបស់ពួកគេក្នុងការធ្វើជាដៃគូជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិល ដូច្នេះពួកគេអាចឈានទៅទទួលបានសេវា និងធនធានសំខាន់ៗ និងបង្កើនឥទ្ធិពលរបស់ពួកគេទៅលើអ្នកធ្វើការសម្រេចចិត្តនានា។

ក្នុងឆ្នាំ២០១១ អង្គការទស្សនៈពិភពលោកបានបន្តពង្រឹងការបំផុសចលនាសហគមន៍តាមរយៈដំណើរការពិគ្រោះយោបល់សហគមន៍ និងផ្សារភ្ជាប់សហគមន៍ជាមួយអាជ្ញាធរថ្នាក់ឃុំ និងស្រុកព្រមទាំងជាមួយអ្នកជំនាញផ្សេងៗក្នុងការកំណត់ឬសគល់បញ្ហាដែលជាមូលហេតុនៃភាក្រីក្រ ហើយផ្តល់នូវដំណោះស្រាយដែលឆ្លើយតបបានល្អបំផុតទៅនឹងការលំបាកនានា ជាពិសេសបញ្ហាសុខភាព និងការអប់រំ។ ការសង្កត់ធ្ងន់ពិសេសគឺទៅលើហានិភ័យនៃភាពក្រីក្រចំពោះកុមារ ហើយនិងការលើកទឹកចិត្តសហគមន៍ឲ្យលើកយកតម្រូវការរបស់កុមារមកពិចារណានៅពេលគេពិភាក្សាផែនការអភិវឌ្ឍរបស់ពួកគេ។ ដើម្បីធានាឲ្យមានការណ៍នេះកើតឡើង គេបង្កើតក្រុមយុវជន និងក្រុមកុមារឡើងដើម្បីប្រមូលសំឡេងរួមរបស់គេក្នុងចំណោមឪពុកម្តាយ អ្នកដឹកនាំសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។



**កូយ សំអន ៦០**
ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

### ការស្ម័គ្រចិត្តដើម្បីការផ្លាស់ប្រែ

កូយ សំអន ចំណាយពេលវេលារបស់គាត់ឲ្យក្រុមសុខភាពភូមិដើម្បីជួយស្ត្រីមានផ្ទៃពោះ សម្រាលកូន និងថែរក្សាសុខភាពទារក។ គាត់និយាយថា "ខ្ញុំធ្វើការស្ម័គ្រចិត្តដើម្បីអ្នកភូមិរបស់ខ្ញុំ ពីព្រោះខ្ញុំស្រលាញ់កុមារទាំងអស់"។

"អ្វីដែលធ្វើឲ្យខ្ញុំសប្បាយចិត្តគឺការអភិវឌ្ឍន៍នៅក្នុងភូមិរបស់ខ្ញុំ។ " សំអនមានភាពជឿជាក់ថា សហគមន៍របស់គាត់នឹងបន្តផ្លាស់ប្តូរកាន់តែប្រសើរឡើង បើទោះជាអង្គការទស្សនៈ-ពិភពលោកបានបញ្ចប់សកម្មភាពការងារក្នុងភូមិរបស់គាត់ក្នុងឆ្នាំ ២០១១ក៏ដោយ។

"ខ្ញុំគិតថា យើងអាចគ្រប់គ្រងកម្មវិធីទាំងអស់នេះបានដោយខ្លួនពួកយើងពីព្រោះខ្ញុំឃើញមានមនុស្សជាច្រើនដែលមានសក្តានុពលនៅក្នុងភូមិរបស់ខ្ញុំ"។



**ក្រុមកុមារហ៊ីបហប**
ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ

### ការធ្វើឲ្យមានការផ្លាស់ប្តូរតាមរយៈការរាំ

ជា សម្ផស្ស មានអាយុ ១៣ឆ្នាំ និយាយថា "ក្រុមកុមារសម្តែងក្បាច់រាំហ៊ីបហប ដែលត្រូវបានបង្កើតឡើងពីក្រុមយុវជននៅក្នុងភូមិរបស់ខ្ញុំ ដែលមានការគាំទ្រពីអង្គការទស្សនៈពិភពលោក បានអញ្ជើញកុមារឲ្យចូលរួមដើម្បីធ្វើឲ្យមានការផ្លាស់ប្រែជាវិជ្ជមាននៅក្នុងភូមិ"។ ក្រុមកុមារសម្តែងក្បាច់រាំហ៊ីបហប ជាកុមារទំនុកបម្រុងរបស់អង្គការទស្សនៈពិភពលោក ទាំង៤រូប រួមមាន៖ សម្ផស្ស និង សាយ នីសួន អាយុ១១ឆ្នាំ សុន រិទ្ធិស័ក អាយុ១០ឆ្នាំ និងណាន សុភារី អាយុ៩ឆ្នាំ។

ក្រុមរបស់ពួកគេត្រូវបានអញ្ជើញឲ្យចូលរួមសម្តែងជាញឹកញាប់ និងសម្តែងរឿងនៅក្នុងសហគមន៍របស់ពួកគេដើម្បីផ្សព្វផ្សាយការយល់ដឹងពីអំពើហិង្សាក្នុងគ្រួសារ សុខភាព ការជួញដូរមនុស្ស និងសិទ្ធិកុមារ។ នៅក្នុងខែមេសា ឆ្នាំ២០១១ ក្រុមកុមារសម្តែងក្បាច់រាំហ៊ីបហប បានចូលរួមជាមួយក្រុមយុវជន៧ក្រុមដើម្បីសម្តែងឲ្យទស្សនិកជនជាង ៥.០០០នាក់ បានទស្សនានៅក្នុងការប្រគំតន្ត្រីខ្នាតធំស្តីពីការអប់រំនៅខេត្តព្រះវិហារ។ ការប្រគំតន្ត្រីមានគោលបំណងដើម្បីអប់រំសហគមន៍ស្តីពីការថែទាំសុខភាព ការសម្អាតបរិស្ថាន សុវត្ថិភាពសហគមន៍ ច្បាប់ភូមិបាល និងច្បាប់ជួញដូរមនុស្ស។



**ញឹម ហ៊ី ៤២**
ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

### ដំណើរឆ្ពោះទៅការបំពេញសេចក្តីត្រូវការសម្រាប់ខ្លួនឯង

ញឹម ហ៊ី ជាប្រធានក្រុមសន្សំ និងជាក្រុមសហគមន៍ប្រាក់កម្ចី នៅក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បាននិយាយថា "ជីវភាពរស់នៅរបស់ប្រជាជនប្រសើរជាងមុន "។

ញឹម ហ៊ី បាននិយាយថា "បច្ចុប្បន្ននេះពួកគេអាចរកលុយបានដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅរបស់ពួកគេ" ដោយយោងទៅលើធនាគារស្រូវនៅក្នុងសហគមន៍របស់គាត់ ដែលបានផ្តល់កម្ចីគ្រាប់ពូជដល់កសិករ។

ហ៊ី បានបន្ថែមទៀតថា "ពីមុន ក្រុមរបស់យើងមានការលំបាកជាច្រើន។ នៅពេលដែលយើងខ្វះខាតថវិកា យើងមិនដឹងថាអ្នកណាអាចជួយយើងបាននោះទេ"។

ប៉ុន្តែសមាជិកម្នាក់បាននិយាយថា "មានក្រុមសន្សំគឺយើងអាចមានកន្លែងទៅរក នៅពេលដែលនរណាម្នាក់ត្រូវការថវិកាបន្ទាន់នោះ"។



# សង្គ្រោះជីវិតទារកនៅ ១.០០០ ថ្ងៃដំបូង

នៅប្រទេសកម្ពុជា កង្វះអាហារូបត្ថម្ភនៅតែបន្តជាឫសគល់នៃបញ្ហាសុខភាពនានា ដែលកុមារ និងម្តាយបានប្រឈម។ ១.០០០ ថ្ងៃដំបូងនៃជីវិតនៅចន្លោះពីការចាប់កំណើតក្នុងផ្ទៃ រហូតដល់ថ្ងៃខួបកំណើតលើកទីពីររបស់ទារក (-៩ ទៅ ២៤ខែ) គឺពេលកំណត់នូវការអភិវឌ្ឍន៍គំនិត និងរាងកាយសមស្របទៅតាមវ័យរបស់ទារក ។ កំឡុងពេលនេះហើយ ជាពេលដែលកុមារងាយរងគ្រោះនឹងកង្វះអាហារូបត្ថម្ភ និងជំងឺនានាបំផុតដែលអាចបណ្តាលឲ្យមានផលប៉ះពាល់ជាអវិជ្ជមានយូរអង្វែងទៅលើអាយុជីវិតកុមារ។

នៅក្នុងឆ្នាំ២០១១ ដើម្បីជីវិតប្រសើរឡើងសម្រាប់កុមារ គឺជាស្នូល និងជាគ្រឹះនៃការងាររបស់យើង កម្មវិធីអភិវឌ្ឍន៍តំបន់ទាំង២៤បានអនុវត្តគម្រោងសុខភាព និងអាហារូបត្ថម្ភដែលផ្តោតលើ ១.០០០ថ្ងៃ ដំបូងនៃជីវិត ក្នុងកិច្ចសហប្រតិបត្តិការជាមួយមណ្ឌលសុខភាពរបស់រដ្ឋាភិបាលទាំង៧០ មណ្ឌលដែលមានស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅកូនដោយទឹកដោះជាង ៥.៤០០នាក់ និងកុមារមានអាយុក្រោម ២ឆ្នាំ មានចំនួន ៦២.០០០នាក់ ទទួលផលពីការងារនេះ។ អង្គការទស្សនៈពិភពលោក និងរដ្ឋាភិបាលរួមគ្នាជាដៃគូធ្វើការងារដូចជា៖

**ម្តាយ** ការថែទាំមុនពេលសម្រាល សម្រាលទារកដោយឆ្មបជំនាញ ការថែទាំក្រោយសម្រាល ការទទួលមីក្រូសារជាតិបន្ថែមក្រោយសម្រាល និងការពន្យារកំណើត

**កុមារ** ចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹល ថ្នាំគ្រាប់បន្ថែមវីតាមីនអា ម្សៅអ៊ូរ៉ាលីត/ ថ្នាំគ្រាប់ជាតិស័ង្កសីសម្រាប់ជំងឺរាក ថ្នាំទំលាក់ព្រូន និងការបន្ថែមជាតិដែក

**គ្រួសារ** ការផ្តើមបំបៅទឹកដោះដំបូង ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ ការផ្តល់អាហារបន្ថែមឲ្យបានត្រឹមត្រូវ ការលាងសម្អាតដៃ និងអំបិលអ៊ីយ៉ូដសម្រាប់ចម្អិនម្ហូបអាហារ

ជាងនេះទៅទៀត នៅតាមគ្រួសារ អង្គការទស្សនៈពិភពលោកកម្ពុជាបានធ្វើការជាមួយសហគមន៍ដើម្បីទទួលបានទឹកសុវត្ថិភាព ហេដ្ឋារចនាសម្ព័ន្ធផ្នែកអនាម័យ និងទម្លាប់អនាម័យខ្លួនប្រាណ ដូច្នេះម្តាយអាចចិញ្ចឹមកូននៅក្នុងបរិស្ថានប្រកបដោយសុខភាពល្អ ជាមួយទឹកស្អាត និងសម្ភារអនាម័យនានាដែលអាចជួយកាត់បន្ថយហានិភ័យពីការឈឺ និងជំងឺឆ្លង។

នៅឆ្នាំថ្មីៗនេះ ប្រទេសកម្ពុជាបានបោះជំហានយ៉ាងវែងក្នុងការកាត់បន្ថយការឆ្លងមេរោគអេដស៍។ អង្គការទស្សនៈពិភពលោកកម្ពុជា បានផ្តោតលើការទប់ស្កាត់ការឆ្លងពីម្តាយទៅកូន ក្នុងកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយកម្មវិធីរបស់ថ្នាក់ជាតិពីរ (NCHADS និង NMCHC) ដើម្បីសម្របសម្រួលការផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍ដល់ស្ត្រីមានផ្ទៃពោះ និងដើម្បីធានាឲ្យបានថាស្ត្រីផ្ទុកមេរោគអេដស៍ ទាំងអស់ទទួលថ្នាំARV និងថ្នាំOI ប្រូហ្វីលាសីស។ អង្គការទស្សនៈពិភពលោកកម្ពុជាក៏បានបន្តធ្វើការជាមួយកុមារកំព្រា និងកុមារងាយរងគ្រោះដោយការឆ្លង និងទទួលរងផលប៉ះពាល់ដោយមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីធានាឲ្យបានថា ពួកគេបានទទួលឱកាសអប់រំ និងវិជ្ជាជីវៈដូចកុមារផ្សេងទៀត និងបន្ថយស្លាកស្នាមទុរយស និងកាត់បន្ថយការរើសអើង។

គ្រប់ការអន្តរាគមន៍ផ្នែកសុខភាព អាហារូបត្ថម្ភ មេរោគអេដស៍ និងជំងឺអេដស៍ និងអនាម័យទឹកស្អាត គឺពិតជាស្របជាមួយកម្មវិធីអាទិភាពរបស់ក្រសួងសុខាភិបាល ដូចទៅនឹងផែនការយុទ្ធសាស្ត្រផ្នែកសុខភាពនីមួយៗ (២០០៨-២០១៥) និងការផ្តួចផ្តើមអនាម័យទឹកស្អាតរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។



### យើងបានជួយទ្រទ្រង់

**ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅកូនដោយទឹកដោះ ជាង ៥.៤០០នាក់ និងកុមារមានអាយុក្រោម ២ឆ្នាំ មានចំនួន ៦២.០០០នាក់**




# ការមានសុខភាពល្អចាប់ផ្តើម សម្រាប់កូនរបស់ស្រីនីន

ភឿន ស្រីនីន អាយុ១៩ឆ្នាំ សម្រាលបានកូនប្រុសជាលើកដំបូងរបស់នាងដែលមានសុខភាពល្អម្នាក់នៅក្នុងមណ្ឌលសុខភាពក្នុងសង្កាត់ស្វាយប៉ាក ក្រុងភ្នំពេញ ដោយគ្មានបារម្ភចំពោះការឆ្លងទន្លេនេះ និងមានការជួយដ៏ច្រើន។

ស្រីនីន និយាយថា "ពេលខ្ញុំដឹងថាមានផ្ទៃពោះ ខ្ញុំសប្បាយចិត្តណាស់ ប៉ុន្តែខ្ញុំក៏មានការព្រួយបារម្ភណាស់ដែរ។ ពីដំបូង ខ្ញុំមិនដឹងថាគួរធ្វើអ្វីដើម្បីសុវត្ថិភាព និងមិនគួរធ្វើអ្វីពេលមានផ្ទៃពោះនោះទេ"។

តាមរយៈចំណេះដឹងដែលស្រីនីន បានទទួលពីបុគ្គលិកមណ្ឌលសុខភាពអន្លង់ក្ងាន នៅជិតផ្ទះរបស់នាង នាងបានរៀនពីរបៀបថែរក្សាសុខភាពរបស់នាង និងពីសារសំខាន់នៃការបំបៅកូនដោយទឹកដោះ។ ទីបំផុតនាងសម្រាលបានកូនប្រុសមានសុខភាពល្អម្នាក់នៅមណ្ឌលសុខភាព។

ស្រីនីន និយាយថា "ខ្ញុំបានទៅមណ្ឌលសុខភាពទៀងទាត់ នៅកន្លែងដែលខ្ញុំទទួលបានការចាក់ថ្នាំបង្ការជំងឺតេតាណូស បន្ថែមគ្រាប់ថ្នាំជាតិដែក និងការធ្វើតេស្តឈាម។ បន្ទាប់ពីការសម្រាលកូនរបស់ខ្ញុំ ខ្ញុំបានទទួលគ្រាប់ថ្នាំជាតិដែកបន្ថែមទៀត។ ខ្ញុំមានការណាត់ជួបជាមួយបុគ្គលិកមណ្ឌលសុខភាពទៀងទាត់ និងយកកូនប្រុសរបស់ខ្ញុំទៅទទួលវ៉ាក់សាំងការពារជំងឺផ្សេងៗដែរ"។

" ការបំបៅកូនដោយទឹកដោះគឺល្អណាស់សម្រាប់កូនរបស់ខ្ញុំ។ វាជួយគេឲ្យមានសុខភាពល្អ និងឆ្លាត..... ហើយខ្ញុំដឹងថា ខ្ញុំគួរតែទទួលទានអាហារដែលមានវីតាមីនដើម្បីឲ្យមានទឹកដោះគ្រប់គ្រាន់សម្រាប់កូនរបស់ខ្ញុំ "

គុណ ស្រីម៉ៅ ជាឆ្មបរបស់មណ្ឌលសុខភាពអន្លង់ក្ងាន ជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលជាច្រើនបាននិយាយថាអង្គការទស្សនៈពិភពលោក ធ្វើសហប្រតិបត្តិការជាមួយសហគមន៍បានយ៉ាងល្អប្រសើរ "អង្គការទស្សនៈពិភពលោក បានជួយមណ្ឌលសុខភាពអន្លង់ក្ងានជាមួយបរិក្ខារពេទ្យល្អៗ សម្រាប់ធ្វើពិសោធ និងសម្រាលកូន។ ឆ្មបជាច្រើននៅក្នុងមណ្ឌលបានទទួលការបណ្តុះបណ្តាលពីការថែរក្សាសុខភាពមាតាតាមរយៈការឧបត្ថម្ភរបស់អង្គការទស្សនៈពិភពលោក"។

# ការរាប់បញ្ចូលសាលាកុមារមេត្រី



អស់រយៈពេលជាច្រើនទសវត្សមកហើយ ប្រទេសកម្ពុជាបានសន្សាបង្កើនចំនួនកុមារគ្រប់រូបឲ្យចុះឈ្មោះចូលរៀន ជាពិសេសនៅកម្រិតបឋមសិក្សា។ ប៉ុន្តែសមត្ថភាព និងចំណេះដឹងរបស់កុមារទាំងអស់ដែលបានចូលរៀននោះពុំសមស្របទៅតាមកម្រិតសិក្សារបស់ពួកគេឡើយដូចជា៖ ការអាន ការសរសេរ ការធ្វើលេខនព្វន្ត និងបំនិនជីវិតជាមូលដ្ឋាន នេះដោយសារតែធនធានក្នុងការបង្រៀនមិនគ្រប់គ្រាន់ សម្ភារ និងសមត្ថភាពបង្រៀនរបស់លោកគ្រូអ្នកគ្រូ និងគ្រូស្ម័គ្រចិត្តនៅមានការខ្វះខាត។

នៅឆ្នាំ២០១១ អង្គការទស្សនៈពិភពលោក បានពង្រីកវិសាលភាពការងាររបស់ខ្លួន ដោយធ្វើការជាមួយសាលារៀនចំនួន៤២៥ ដោយនៅឆ្នាំ២០១០ មានតែសាលារៀនចំនួន៣៥៣ ប៉ុណ្ណោះនៅក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ទាំង២៦។ហើយអង្គការបានចាប់ផ្តើមកែប្រែកម្មវិធីអប់រំរបស់ខ្លួន ដោយធ្វើការផ្តោតលើការធានាឲ្យកុមារទៅសាលារៀន និងកែប្រែឲ្យសាលារៀនក្លាយជាមេត្រីភាព និងទាក់ទាញកុមារឲ្យចង់ទៅរៀនសូត្រ។ គោលបំណងសំខាន់គឺចង់ឲ្យកុមារគ្រប់រូប ជាពិសេសកុមារី អាចបញ្ចប់កម្រិតសិក្សាថ្នាក់មូលដ្ឋានរបស់ខ្លួនប្រកបដោយសមត្ថភាពទៅលើការអាន ការសរសេរអក្សរ ការធ្វើលេខនព្វន្ត និងបំនិនជីវិត និងមានឱកាសដើម្បីបន្តការសិក្សានៅកម្រិតអនុវិទ្យាល័យទៀត។

ដើម្បីសម្រេចបានគោលបំណងនេះ អង្គការទស្សនៈពិភពលោក បានពង្រឹងក្រុមសហគមន៍ និងស្ថាប័នក្នុងតំបន់ដើម្បីស្វែងរកមតិគាំទ្រសម្រាប់គុណភាពដើម្បីឲ្យមានគុណភាពក្នុងការអប់រំកុមារតូចៗ ការអប់រំថ្នាក់មូលដ្ឋាន និងបំនិនជីវិត។ តាមរយៈការអនុវត្តនូវទ្រឹស្តី សំឡេង និងសកម្មភាពប្រជាពលរដ្ឋ សហគមន៍អាចមានសមត្ថភាពនិយាយទៅកាន់ស្ថាប័នអប់រំនៃការបង្រៀន ការផ្តល់ឱកាសប្រកបដោយសុវត្ថិភាព និងមានបរិស្ថានល្អដែលអាចឲ្យកុមារគ្រប់រូបទទួលបាននូវការសិក្សាប្រកបដោយគុណភាព។

អង្គការទស្សនៈពិភពលោកក៏បានពង្រឹងការផ្តល់វគ្គបណ្តុះបណ្តាលជូនលោកគ្រូ អ្នកគ្រូ និងអ្នកស្ម័គ្រចិត្តអំពីទ្រឹស្តីសិស្សមជ្ឈមណ្ឌល និងជួយបង្កើតឲ្យមានសម្ភារសម្រាប់សិក្សា និងធនធានបង្រៀននានាសម្រាប់លោកគ្រូអ្នកគ្រូ គ្រូស្ម័គ្រចិត្ត និងសិស្សានុសិស្សតាមរយៈការចាប់ដៃគូជាមួយក្រសួងអប់រំយុវជន និងកីឡា។ ដើម្បីធានានូវការរីកចម្រើនប្រកបដោយនិរន្តរភាព អង្គការទស្សនៈពិភពលោក បានរួមបញ្ចូលសហគមន៍ជាមួយសកម្មភាពរបស់ខ្លួនជាពិសេសគណៈកម្មាការទ្រទ្រង់សាលា និងសមាគមន៍មាតាបិតា និងគ្រូបង្រៀន។

ឆ្នាំកន្លងមកអង្គការទស្សនៈពិភពលោក បានធ្វើការលើកកម្ពស់ការអភិវឌ្ឍន៍បំនិនជីវិត ដែលរួមមាន៖ បំនិនពិចារណាហ្មត់ចត់ បំនិនការគ្រប់គ្រងអារម្មណ៍ បំនិនទំនាក់ទំនង បំនិនធ្វើការជាក្រុម និងបំនិនទទួលខុសត្រូវកិច្ចការសង្គម ការងារនេះធ្វើតាមរយៈក្លិបកុមារ និងយុវជននៅតាមសាលារៀនចំនួន១២១ និងក្លិបនៅតាមសហគមន៍ចំនួន២០៣ដែលមានកុមារជាង ១៥.០០០នាក់ បានចូលរួម។ ការចូលរួមនៅក្នុងក្លិបទាំងអស់នេះ អាចជួយឲ្យកុមារក្លាយជាភ្នាក់ងារនៃការផ្លាស់ប្រែ ដែលអាចជួយឲ្យកុមារផ្សេងទៀតក្លាយជាប្រជាពលរដ្ឋប្រកបដោយសមត្ថភាព និងមានប្រយោជន៍ក្នុងសង្គម។

## សំឡេង និងសកម្មភាពប្រជាពលរដ្ឋមានគោលបំណងដើម្បី៖

១. បង្កើនកិច្ចពិភាក្សារវាងប្រជាពលរដ្ឋទូទៅ និងស្ថាប័នដែលផ្តល់សេវាសាធារណៈ

២. ពង្រឹងគណនេយ្យភាពនៃស្ថាប័នរដ្ឋបាល និងនយោបាយរបស់រដ្ឋាភិបាល ដើម្បីបង្កើនគុណភាពសេវាកម្មសាធារណៈ

៣. ផ្តល់អំណាចដល់សហគមន៍ឲ្យចេះប្រើប្រាស់អំណាចដើម្បីឲ្យសេវាកម្មសាធារណៈមានគុណភាពប្រសិទ្ធភាព និងតម្លាភាព

៤. ពង្រឹងទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាលតាមរយៈការអប់រំ និងផ្តល់អំណាចដល់សហគមន៍ឲ្យចេះនិយាយទៅកាន់អ្នកផ្តល់សេវាកម្ម និងមន្ត្រីរដ្ឋាភិបាល ស្តីពីការអនុវត្តន៍សេវាកម្មសាធារណៈសំខាន់ៗ។




# វិជ្ជរ៉ាចូលចិត្តការអាន

វិជ្ជរ៉ា មានអាយុ ១២ឆ្នាំ បាននិយាយថា "តាមរយៈការអានសៀវភៅក្នុងបណ្ណាល័យ ខ្ញុំរៀនបានយ៉ាងច្រើនអំពីការដាំត្រកួន ស្ពៃក្តោប ប៉េងប៉ោះ និងឆៃថាវ"។

វិជ្ជរ៉ា និងមិត្តភ័ក្ត្ររបស់នាងមានកាលវិភាគមកអានសៀវភៅ និងលេងល្បែងកំសាន្តនៅក្នុងបណ្ណាល័យពីរដងក្នុងមួយសប្តាហ៍នៅរៀងរាល់ថ្ងៃពុធ និងថ្ងៃសៅរ៍។

លោកសៀន ថន ជានាយកសាលាបឋមសិក្សាភូមិថ្មី មានប្រសាសន៍ថា "សព្វថ្ងៃនេះ មានសិស្សជាច្រើនចូលចិត្តអានសៀវភៅ ហើយកុមារៗមានគំនិតថ្មីៗចាប់តាំងពីពួកគេបានអនុវត្ត និងប្រើប្រាស់សម្ភារនៅក្នុងបណ្ណាល័យ"។

"ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការទស្សនៈពិភពលោក ដែលបានយកចិត្តទុកដាក់ទៅលើកិច្ចការអភិវឌ្ឍន៍នៅក្នុងសហគមន៍។ ពេលប្រជាជនសហគមន៍មានការរស់នៅដ៏ប្រសើរ កូនៗរបស់ពួកគេក៏មានឱកាសបានទៅសាលារៀនដែរ"។

លោក ថន មានប្រសាសន៍ថា "អង្គការទស្សនៈពិភពលោកកម្ពុជាបានគាំទ្រលោកគ្រូអ្នកគ្រូ និងលើកទឹកចិត្តពួកគេឲ្យខិតខំធ្វើការដើម្បីនាំមកនូវគុណភាពអប់រំ "។

នៅក្នុងឆ្នាំ២០១២ លោក ថន មានផែនការជាមួយសិស្សរបស់គាត់រៀបចំព្រឹត្តិការណ៍ផ្សព្វផ្សាយស្តីពីការអប់រំនៅក្នុងសហគមន៍។ គាត់មានប្រសាសន៍ "យើងចង់ឲ្យប្រជាជនគ្រប់រូបឲ្យតម្លៃការអប់រំ និងលើកទឹកចិត្តកូនៗរបស់ពួកគេបន្តការសិក្សា"។

ដោយការផ្តោតលើការធ្វើឲ្យគុណភាពនៃការអប់រំបានប្រសើរឡើង អង្គការទស្សនៈពិភព-លោក បានសម្របសម្រួលជាមួយជនបង្គោលអំពីការបណ្តុះបណ្តាលគរុកោសល្យដល់លោកគ្រូអ្នកគ្រូនៅក្នុងសាលាបឋមសិក្សាចំនួន១២ដែលមានទីតាំងនៅក្នុងស្រុកព្រៃកស្តេចខ្ពបអាទាវ និងឃុំពាមរាំងក្នុងខេត្តកណ្តាល និងធ្វើទស្សនៈកិច្ចសិក្សាសាលាគំរូនានា។ អង្គការទស្សនៈពិភពលោកក៏បានបរិច្ចាគសៀវភៅអានជាច្រើន និងសម្ភារសាលារៀនជាច្រើនទៀត និងផ្តល់នូវជំនាញគ្រប់គ្រងបណ្ណាល័យឲ្យបណ្ណារក្សផងដែរ។

"ខ្ញុំចូលចិត្តវិធីសាស្រ្តដែលលោកគ្រូអ្នកគ្រូបង្រៀនយើង។ យើងធ្វើកិច្ចការដែលតម្រូវឲ្យយើងអានសៀវភៅជាច្រើនក្នុងបណ្ណាល័យ"



# ការការពារកុមារគឺត្រូវចាប់ផ្តើមនៅផ្ទះ ដើម្បីសុវត្ថិភាពប្រសើរឡើងនៅកម្ពុជា

ប្រសិនបើគ្មានបរិស្ថានមួយដែលមានសុវត្ថិភាព និងប្រកបដោយការការពារនៅក្នុងផ្ទះ ក្នុងក្រុមគ្រួសារ និងសហគមន៍របស់ពួកគេទេនោះ កុមារមុខជាងាយរងគ្រោះដោយការរំលោភបំពានច្រើនទម្រង់ណាស់ ហើយគេក៏គ្មានការជួយគាំទ្រឲ្យបានសមស្រប និងទាន់ពេលដែរ នៅពេលមានការរំលោភបំពានណាមួយបានកើតឡើងចំពោះពួកគេ។ ម្យ៉ាងទៀត ដោយហេតុតែមានភាពទ័លក្រនៅក្នុងគ្រួសារ ហើយដោយមានពាក្យសន្យាថានៅទីក្រុង និងបរទេសមានជីវភាពល្អប្រសើរជាង នៅតែជំរុញទឹកចិត្តយុវជនកម្ពុជាឲ្យធ្វើចំណាកស្រុក ទៅរកទីក្រុង ឬឆ្លងព្រំដែនទៅប្រទេសថៃ នោះភាពប្រថុយប្រថាននៃការធ្វើចំណាកស្រុកដែលគ្មានសុវត្ថិភាព ហើយភាពងាយរងគ្រោះដោយការជួញដូរ មានកាន់តែខ្ពស់ដែលគួរឲ្យព្រួយបារម្ភ។

ក្នុងឆ្នាំ២០១១ អង្គការទស្សនៈពិភពលោកបានបន្តពង្រឹង និងពង្រីកយន្តការសម្រាប់ការការពារកុមារ ដោយផ្តោតការយកចិត្តទុកដាក់នៅថ្នាក់មូលដ្ឋានក្នុងតំបន់គោលដៅនៃកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួនបួនដែលមានប្រជាជនជាង ៧.០០០នាក់ បានទទួលផលប៉ះពាល់។ ប្រជាជនទាំងនោះរួមមាន មន្ត្រីភូមិ និងឃុំ នគរបាលមូលដ្ឋាន កុមារ និងយុវជន២.៩០០នាក់ ទទួលបានការយល់ដឹង និងចូលរួមទប់ស្កាត់បង្ការមិនឲ្យមានការរំលោភបំពានគ្រប់ទម្រង់ទាំងអស់ ឧទាហរណ៍ អំពើហិង្សាក្នុងគ្រួសារ អំពើកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មធ្ងន់ធ្ងរ និងការជួញដូរមនុស្ស។ យន្តការទាំងនោះ រួមមានការរួមសហការការងារជាមួយសហគមន៍ ដើម្បីបង្កើនការយល់ដឹង ធ្វើឲ្យមានការផ្លាស់ប្តូរឥរិយាបថបែរមករកការការពារសិទ្ធិកុមារ គឺឲ្យពួកគេមានការយល់ដឹងកាន់តែខ្លាំងឡើងអំពីសារសំខាន់នៃការការពារកុមារ។ អង្គការយើងបានផ្តោតការយកចិត្តទុកដាក់ពិសេសចំពោះកុមារចំនួន១.៤០០នាក់ដែលកំពុងស្ថិតក្នុងស្ថានភាពជាពលករ និងកុមារមួយចំនួនធំទៀតដែលងាយនឹងធ្លាក់ក្នុងស្ថានភាពជាពលករ នៅក្នុងតំបន់ទីក្រុង និងជនបទចំនួន ៨កន្លែង ដោយប្រើយន្តការបំផុសឲ្យមានការចូលរួមពីកុមារ ឪពុកម្តាយ ម្ចាស់សិប្បកម្ម និងអាជ្ញាធរមូលដ្ឋាន ដើម្បីកាត់បន្ថយ និងទប់ស្កាត់បង្ការមិនឲ្យមានពលកម្មកុមារក្នុងរោងចក្រ (សិប្បកម្ម)ឡឥដ្ឋ។

តាមរយៈការបំផុសកុមារ និងសហគមន៍ឲ្យរៀនយល់ដឹងអំពីសិទ្ធិជាមូលដ្ឋានរបស់គេ ហើយឲ្យគេចេះនូវរបៀបកត់សម្គាល់បណ្តាស្ថានភាព ឬអាកប្បកិរិយាដែលគួរឲ្យសង្ស័យ ឬដែលងាយមានគ្រោះថ្នាក់ នោះយើងបានធ្វើឲ្យប្រជាជនក្នុងសហគមន៍ទទួលបានការបំពាក់បំប៉នឲ្យចេះទប់ស្កាត់បង្ការ និងចេះរាយការណ៍អំពីអំពើរំលោភនានាក្នុងសហគមន៍របស់គេ។ សមាជិកក្នុងសហគមន៍បានបង្កើត និងចងក្រងជាតួនាទីនិងទំនួលខុសសម្រាប់សមាជិករបស់ខ្លួនដើម្បីឆ្លើយតបរាល់ហេតុការណ៍រំលោភ ដោយសហការជាមួយអាជ្ញាធរអនុវត្តប្រចាំមូលដ្ឋានគេ។


កុមារីរងគ្រោះពីការជួញដូរទទួលបានការថែទាំ និងព្យាបាលនៅមណ្ឌលនាវាថ្មី


មិត្តអប់រំមិត្តអានរឿងឲ្យកុមាររស់នៅតាមផ្លូវស្តាប់និងបង្រៀនពួកគេពីការរក្សាអនាម័យ និងពីរបៀបការពារខ្លួនពួកគេ

ក្លិបកុមារ និងយុវជនបានផ្តល់បរិស្ថានប្រកបដោយសុវត្ថិភាពសម្រាប់កុមារ ដើម្បីរៀនពីវិធីការពារខ្លួនពីការរំលោភបំពាន និងដឹងពីអ្វីដែលអាចជួយពួកគេបានប្រសិនបើពួកគេត្រូវទទួលរងនូវការរំលោភបំពាន ឬដឹងថាមានជនរងគ្រោះណាម្នាក់ទទួលរងនូវការរំលោភបំពាន។

## ការជាសះស្បើយពីការប៉ះទង្គិចផ្លូវចិត្ត

ក្នុងឆ្នាំ២០១១ គម្រោងស្តារនីតិសម្បទាកុមារីរងគ្រោះរបស់អង្គការទស្សនៈពិភពលោកបានស្តារនីតិសម្បទា និងសមាហរណកម្មកុមារីរងគ្រោះចំនួន ៣៤នាក់ ដែលត្រូវបានទទួលរងគ្រោះដោយការជួញដូរកេងប្រវ័ញ្ចផ្លូវភេទនិងការរំលោភបំពានផ្លូវភេទ។ គម្រោងស្តារនីតិសម្បទាកុមារីរងគ្រោះ (មណ្ឌលនាវាថ្មី) របស់អង្គការទស្សនៈពិភពលោកបានផ្តល់នូវតម្រូវការចាំបាច់ វគ្គបណ្តុះបណ្តាលជំនាញ និងការអប់រំ ការថែទាំសុខភាពផ្លូវកាយ និងផ្លូវចិត្ត។ អង្គការទស្សនៈពិភពលោកបានធ្វើការផងដែរជាមួយអាជ្ញាធរប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សរបស់រាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយបញ្ហាការរំលោភផ្លូវភេទ និងការជួញដូរកុមារីក្នុងប្រទេសកម្ពុជា។

តាមរយៈដៃគូនានា អង្គការទស្សនៈពិភពលោកបានផ្តល់ការគាំទ្រដល់កុមារា និងកុមារីចំនួនជាង ២០០នាក់ ដែលត្រូវបានជួញដូរនិងរំលោភបំពានផ្លូវភេទ។ យើងធ្វើការបញ្ជូនបុរស និងស្ត្រីដែលត្រូវបានជួញដូរ និងផ្តល់ការធ្វើសមាហរណកម្មឲ្យពួកគេត្រឡប់ទៅសហគមន៍វិញ។

## រក្សាសុវត្ថិភាពកុមារនៅតាមដងផ្លូវ

អង្គការទស្សនៈពិភពលោកបានបន្តធ្វើការជាមួយកុមារធ្វើការ និងរស់នៅតាមដងផ្លូវក្នុងរាជធានីភ្នំពេញតាមរយៈការផ្តល់ជម្រកសុវត្ថិភាព ចំណីអាហារ ការអប់រំក្រៅប្រព័ន្ធដល់កុមារចំនួន ៣៨នាក់ នៅក្នុងមជ្ឈមណ្ឌលកុមារទំពាំងស្នងឬស្សី ក្រុមការងារពេលយប់បានចុះធ្វើការជាមួយកុមារតាមផ្លូវចំនួន ៣.០០០នាក់ដោយផ្តល់នូវការសង្គ្រោះបឋម និងការលើកកម្ពស់ការយល់ដឹងស្តីពីសិទ្ធិកុមារ មេរោគអេដស៍និងជំងឺអេដស៍ ការប្រើប្រាស់គ្រឿងញៀន អនាម័យ និងការជួញដូរកុមារ។






# ពីឡឥដ្ឋ ទៅកាន់សៀវភៅ និងប៊ិចវិញ

" ខ្ញុំជាកុមារម្នាក់ក្នុងចំណោមកុមារជាច្រើននាក់ ដែលធ្វើការនៅក្នុងឡឥដ្ឋបានត្រលប់ទៅសាលារៀនវិញ ។ មានអ្នកជិតខាងជាច្រើនបានសួរខ្ញុំ និងសួរពីការសិក្សារបស់ខ្ញុំយ៉ាងម៉េចដែរ ។ ហើយពួកគេសរសើរខ្ញុំពេលខ្ញុំអានសៀវភៅឲ្យពួកគេស្តាប់ "

សាឡៃមានអាយុ១៣ឆ្នាំ ធ្លាប់ធ្វើការក្នុងឡឥដ្ឋជំនួសឲ្យការទៅសាលារៀនដើម្បីជួយគ្រួសាររបស់គាត់ដោះបំណុលទៅម្ចាស់ឡឥដ្ឋ ។ សាឡៃ និយាយថា "ឪពុកម្តាយរបស់ខ្ញុំពិតជាចង់ឲ្យខ្ញុំទៅសាលារៀន ប៉ុន្តែពួកគាត់គ្មានលទ្ធភាពទេ ដូច្នេះខ្ញុំពិតជាគ្មានសំណាងទេ"។

កាលពីមុនគ្រួសាររបស់សាឡៃមិនបានខ្វាយខ្វល់ពីការសិក្សាទេ ពីព្រោះចំពោះពួកគេ អាហារគឺសំខាន់ជាង។ សាឡៃ និយាយថា "យើងបានខំធ្វើការទាំងអស់គ្នានៅក្នុងឡឥដ្ឋ ដើម្បីរកលុយទិញអាហារហូប ខ្ញុំស្រលាញ់ការសិក្សាណាស់ ហើយខ្ញុំគឺចង់ក្លាយជាជាងជួសជុលម៉ូតូម្នាក់ ពីព្រោះខ្ញុំគិតថាវាស្រួលជាងធ្វើការនៅក្នុងឡឥដ្ឋដ៏ក្តៅហែងបែបហ្នឹងណាស់"។

"បុគ្គលិកអង្គការទស្សនៈពិភពលោក បានលើកទឹកចិត្តខ្ញុំឲ្យចូលសាលារៀន ហើយខ្ញុំសប្បាយចិត្តណាស់ពីព្រោះទីបំផុតឪពុកម្តាយរបស់ខ្ញុំបានអនុញ្ញាតឲ្យខ្ញុំចូលរៀនក្នុងមណ្ឌលសំចត ប៉ុន្តែបងប្រុសខ្ញុំផ្សេងទៀតមិនបានចូលរៀនទេពីព្រោះពួកគេត្រូវជួយឪពុកម្តាយរបស់ខ្ញុំធ្វើការក្នុងឡឥដ្ឋ"។ សាឡៃ បានត្រូវធ្វើសមាហរណកម្មត្រឡប់ទៅផ្ទះគាត់វិញហើយ។ សាឡៃ និយាយថា "ខ្ញុំទទួលបានកង់មួយ ហើយខ្ញុំជិះវាដោយមោទនភាពទៅសាលាជារៀងរាល់ថ្ងៃ។កង់នេះពិតជាលើកទឹកចិត្តខ្ញុំឲ្យខំរៀនសូត្រ ហើយខ្ញុំជាសិស្សពូកែម្នាក់សព្វថ្ងៃនេះ"។

សាឡៃ បានបន្ថែមថា "មានកុមារជាច្រើនដែលធ្វើការក្នុងឡឥដ្ឋនៅកន្លែងដែលខ្ញុំបានធ្វើ ក៏បានទៅសាលារៀនដែរឥឡូវនេះ។ អ្នកជិតខាងខ្លះនិយាយថា ខ្ញុំបានធ្វើជាគំរូដ៏ល្អចំពោះអ្នកផ្សេងទៀតក្នុងនាមជាមនុស្សដែលស្រលាញ់ការសិក្សា។ ឪពុកម្តាយរបស់ខ្ញុំ បុគ្គលិកអង្គការទស្សនៈពិភពលោក កុមារផ្សេងទៀត និងអ្នកជិតខាងរបស់ខ្ញុំគឺពិតជាពេញចិត្ត និងលើកទឹកខ្ញុំឲ្យខិតខំរៀនសូត្រ"។

អង្គការទស្សនៈពិភពលោក បានឧបត្ថម្ភគ្រួសាររបស់សាឡៃក្នុងការជួយរកប្រាក់ចំណូលដោយផ្តល់សម្ភារកាត់សក់។ ឪពុករបស់សាឡៃចេះកាត់សក់ ហើយឥឡូវនេះ គាត់អាចរកប្រាក់បានពី ១0.000 រៀល ទៅ ១៥.000រៀល ក្នុងមួយថ្ងៃ(២,៥0 ដុល្លារ ទៅ ៣,៧៥ដុល្លារ)។

# សន្សំប្រាក់ និងរកចំណូលដើម្បីអនាគតកូន។

ទំហំគ្រួសារក្រីក្របំផុតនៅកម្ពុជានៅតែពឹងផ្អែកលើរបរកសិកម្មសម្រាប់ជីវភាពរស់នៅរបស់ពួកគេ ពួកគេនៅតែគ្មានជំនាញ ហើយប្រកបរបរចិញ្ចឹមជីវិតតាមរយៈការងារមិនទៀងទាត់ និងមិនពិតប្រាកដ ដែលទាំងនេះបង្ខំពួកគេធ្លាក់ចូលក្នុងការធ្វើចំណាកស្រុក បណ្ដាលឲ្យកើនឡើងនូវភាពងាយរងគ្រោះចំពោះកុមារ។



ក្នុងឆ្នាំ២០១១ អង្គការទស្សនៈពិភពលោកបានគិតលើការអភិវឌ្ឍន៍សេដ្ឋកិច្ច និងកសិកម្ម តាមរយៈកិច្ចអន្តរាគមន៍បែបណាមួយដែលអាចមានផលប៉ះពាល់ដោយផ្ទាល់ដល់កុមារ។ បើទោះទីបញ្ចប់ចំណូលទាំងនោះមិនបានបង្ហាញឲ្យឃើញជារូបរាងយ៉ាងណាក្ដី ប៉ុន្តែន័យមួយគឺដើម្បីជីវិតប្រសើរឡើងសម្រាប់កុមារ។ ដោយធ្វើការក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន ២៧ និងតាមយៈគម្រោងសំខាន់ៗទាំងបីផ្នែក អង្គការទស្សនៈពិភពលោកបានផ្ដោតម្ដងទៀតលើផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច និងកសិកម្ម ដោយឆ្ពោះទៅគោលដៅបី ដូចខាងក្រោម៖

**ការសម្របសម្រួលលើអាជីវកម្ម** ប្រមើលមើលឱកាសសេដ្ឋកិច្ចក្នុងស្រុកសម្រាប់គ្រួសារ និងសហគមន៍ និងអភិវឌ្ឍកសិកម្មតាមតំបន់ចំពោះការដាំដំណាំ និងចិញ្ចឹមសត្វ ដែលអាចឲ្យកសិករចែកចាយព័ត៌មាន រួមគ្នាចរចារតម្លៃ ហើយនិងអភិវឌ្ឍជំនាញរបស់ពួកគេ។ ការបង្រៀនសហគមន៍ឲ្យចេះវិភាគអាជីវកម្ម ដាក់គោលដៅ ធ្វើផែនការ និងសម្របសម្រួលឲ្យចេះរកនូវអានុភាពដែលគាត់ត្រូវការ។

មានកសិករចំនួន ៧០០នាក់ បានទទួលផលពីការចូលរួមវាយតម្លៃអត្ថប្រយោជន៍ប្រកួតប្រជែងការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ និងឱកាសរកប្រាក់ចំណូល។ ជាលទ្ធផល កសិករចិញ្ចឹមជ្រូកទទួលការបណ្ដុះបណ្ដាលចិញ្ចឹមជ្រូកពូជឲ្យធំធាត់ក្នុងរយៈពេលតែ៤ខែ អាចទទួលបាន៥០ដុល្លារសហរដ្ឋអាមេរិក ដែលពីមុនគាត់ចំណាយពេលពី ៦ ទៅ ៧ខែ ប៉ុន្តែអាចទទួលផលបានត្រឹមតែ ៣៥ដុល្លារសហរដ្ឋមេរិកប៉ុណ្ណោះ។ កសិករដាំបន្លែដែលបានរៀន ពួកគេក៏អាចដាំបន្លែនៅក្នុងរដូវវស្សាដោយប្រើប្រាស់បច្ចេកទេសដែលមានស្រាប់ ហើយអាចឲ្យពួកគេទទួលបានទិន្នផលច្រើនជាងមុនពីរដងក្នុងមួយឆ្នាំ។ កសិករដាំពោត បានចងក្រងគ្នាជាសមាគមន៍នានាដែលអាចឲ្យពួកគេមានសំឡេងក្នុងការកំណត់តម្លៃ។ ដោយសារសំឡេងប្រមូលផ្ដុំរបស់ពួកគេ តម្លៃពោតបានកើនឡើងពី ០.១ដុល្លារអាមេរិកទៅ០.២ដុល្លារក្នុងមួយគីឡូក្រាមដូច្នេះកសិករទាំងអស់អាចទិញគ្រាប់ពូជបានភ្លាមៗ ពួកគេអាចដាំពោតបាន៣ដងក្នុងមួយឆ្នាំ។

**លើកស្ទួយការសន្សំប្រាក់** បង្កើតទម្លាប់សន្សំសំចៃក្នុងចំណោមគ្រួសារក្រីក្រ និងអភិវឌ្ឍជំនាញដើម្បីមីក្រូហិរញ្ញវត្ថុ។

នៅដំណាច់ឆ្នាំ២០១១ មានអ្នកសន្សំប្រាក់ជាង៤១.០០០នាក់នៅតាមកម្មវិធីអភិវឌ្ឍន៍តំបន់អង្គការទស្សនៈពិភពលោក ដែលគិតជាសាច់ប្រាក់សរុបជិត២០០.០០០ដុល្លារសហរដ្ឋអាមេរិក។

**ភ្ជាប់ទៅនឹងសង្វាក់តម្លៃ** ផ្សារភ្ជាប់អ្នកផលិតជាមួយស្ថាប័នសាធារណៈ និងឯកជន ហើយនិងពាណិជ្ជករ ដែលបានធ្វើដំណើរទៅកាន់ទីផ្សារកាន់តែធំទូលាយសម្រាប់ផលិតផលសហគមន៍។

អភិបាលរងស្រុកសំឡូតបានរាយការណ៍ថាការទំនាក់ទំនងរបស់ពួកគេជាមួយសហគមន៍បានបើកភ្នែកពួកគេហើយសម្លឹងរួមគ្នាឆ្ពោះទៅសក្ដានុពលនៃតំបន់របស់ពួកគេ។ ពួកគេគឺអាចកំណត់បាននូវអ្វីដែលពួកគេហៅថាគ្រាប់ពូជយុទ្ធសាស្ត្រសំខាន់ក្នុងសហគមន៍ទាំងប្រាំពីរដែលបានចូលរួម និងធ្វើផែនការចូលរួមផ្សព្វផ្សាយគ្រាប់ពូជទៅកាន់ពាណិជ្ជករនៅខាងក្រៅ។

អង្គការទស្សនៈពិភពលោកនឹងបន្តធ្វើការជាដៃគូជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧត្ដុនិយម ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទដើម្បីបង្កើនសកម្មភាពអន្តរាគមន៍ផ្នែកកសិកម្មនិងសេដ្ឋកិច្ច និងអនុវត្តការងារទាំងនេះក្នុងផ្លូវមួយដែលនាំឲ្យជីវិតកុមារប្រសើរឡើង។




# ការចញ្ចឹមបសុសត្វធ្វើឲ្យសារិន មានទស្សនវិស័យដ៏ភ្លឺស្វាង

"ខ្ញុំបានបម្រើសហគមន៍របស់ខ្ញុំចាប់តាំងពីឆ្នាំ២០០១ មកម្ល៉េះ។ អង្គការទស្សនៈពិភពលោកបានអញ្ជើញខ្ញុំឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាច្រើន ដើម្បីកសាងសមត្ថភាពរបស់ខ្ញុំក្នុងផ្នែកកសិកម្ម"

សារិន អាយុ៤០ឆ្នាំ និយាយថា "មានការផ្លាស់ប្រែច្រើនណាស់នៅក្នុងភូមិខ្ញុំ។ ពីមុនគ្រួសារខ្លះគ្មានគោមួយក្បាលទេ ប៉ុន្តែឥឡូវនេះពួកគេមានគោ ២ ទៅ ៣ ក្បាលនៅក្នុងគ្រួសារនីមួយៗ។ លក្ខខណ្ឌការរស់នៅរបស់ប្រជាជនគឺប្រសើរច្រើន គ្រួសារនីមួយៗមានផ្ទះធំៗសព្វថ្ងៃនេះ។ ប្រជាជនបានបញ្ជូនកូនៗរបស់ពួកគេទៅសាលារៀន និងមានលទ្ធភាពទិញកង់ដូច្នេះកូនៗអាចជិះទៅសាលារៀនបាន។ ប្រជាជននៅក្នុងសហគមន៍របស់ខ្ញុំ មានអាហារគ្រប់គ្រាន់ទទួលទាន និងមានសុខភាពល្អ"។

សារិន រស់នៅខេត្តកំពង់ឆ្នាំង មានកូនស្រី២នាក់ជាកុមារទំនុកបម្រុង គាត់និយាយទាំងមោទនភាពថា "ខ្ញុំបានបម្រើសហគមន៍របស់ខ្ញុំតាំងពីឆ្នាំ២០០១មកម្ល៉េះ។ អង្គការទស្សនៈពិភពលោកកម្ពុជា បានអញ្ជើញខ្ញុំឲ្យចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដើម្បីកសាងសមត្ថភាពរបស់ខ្ញុំក្នុងការគ្រប់គ្រង ជាពិសេសលើវិស័យកសិកម្ម។ សារិនបានទទួលចំណេះដឹង និងមានប្រយោជន៍ចំពោះគ្រួសារគាត់ផ្ទាល់ និងគ្រួសារនានានៅក្នុងភូមិរបស់គាត់។ អរគុណវគ្គបណ្តុះបណ្តាលរបស់អង្គការទស្សនៈពិភពលោក ដែលបានឲ្យគាត់ និងគ្រួសារផ្សេងទៀតបានចូលរួម និងបានធ្វើឲ្យប្រាក់ចំណូលរបស់ពួកគេប្រសើរឡើង។

សារិន និយាយទាំងមោទនភាពថា "ចំណេះដឹងមានសារសំខាន់ណាស់ ពីមុនខ្ញុំជាកសិករធម្មតា ហើយខ្ញុំគ្មានបច្ចេកទេសចិញ្ចឹមបសុសត្វទេ។ ខ្ញុំរៀនបានច្រើនពីវគ្គបណ្តុះបណ្តាលជាមួយអង្គការទស្សនៈពិភពលោក។ ឥឡូវនេះខ្ញុំមានសមត្ថភាពចិញ្ចឹមសត្វមានប្រសិទ្ធភាពជាងមុន។ ខ្ញុំក៏បានចែកចាយបច្ចេកទេសដែលខ្ញុំរៀនពីរបៀបចិញ្ចឹមសត្វជាមួយប្រជាជនផ្សេងទៀតនៅក្នុងភូមិ"។

គាត់ និយាយថា "បន្ទាប់ពីបានទទួលវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមសត្វតាមរយៈកម្មវិធីរបស់អង្គការទស្សនៈពិភពលោកខ្ញុំបានចិញ្ចឹមជ្រូកពី ៣០ ទៅ ៤០ក្បាល ហើយប្រាក់ចំណូលរបស់ខ្ញុំកើនច្រើនណាស់។ ខ្ញុំអាចរកលុយបានយ៉ាងហោចណាស់ ១.០០០ដុល្លារ ក្នុងមួយសារៗ ហើយលុយត្រូវបានប្រើប្រាស់ផ្គត់ផ្គង់កូនៗរបស់ខ្ញុំទៅរៀន និងខ្ញុំបានទិញដីជាច្រើនកន្លែងដើម្បីធ្វើកសិកម្ម។ ឥឡូវខ្ញុំក៏កំពុងធ្វើជាពេទ្យសត្វដើម្បីរកប្រាក់ចំណូលបន្ថែម"។



# បំពងសំឡេងសហគមន៍

នៅពេលណាដែលអង្គការទស្សនៈពិភពលោកអាចនឹងតស៊ូមតិជំនួសប្រជាជនដែលយើងធ្វើការជាមួយ នោះគឺគ្មានប្រសិទ្ធភាពអ្វីដែលប្រសើរជាងសហគមន៍អាចនិយាយដោយខ្លួនឯងដើម្បីមានការផ្លាស់ប្តូរនោះទេ។ សំឡេងរបស់កុមារ និងសហគមន៍ គឺជាគ្រឿងផ្សំដ៏សំខាន់សម្រាប់បង្កើតឲ្យមានការផ្លាស់ប្រែប្រកបដោយនិរន្តរភាពយ៉ាងពិតប្រាកដសម្រាប់ជីវិតរស់នៅរបស់ពួកគាត់។

ក្នុងឆ្នាំ២០១១ អង្គការទស្សនៈពិភពលោកធ្វើការយ៉ាងជិតស្និទជាមួយសហគមន៍ ពិសេសកុមារ ដោយកសាងទំនុកចិត្តតស៊ូមតិតាមមូលដ្ឋានតាមរយៈបង្កើនចំណេះដឹងផ្នែកសិទ្ធិមូលដ្ឋានរបស់ពួកគេ ការកំណត់នូវការប្រឈមសំខាន់ៗបំផុត ហើយវិធីសាស្ត្រដែលពួកគេចង់អភិវឌ្ឍ និងការបង្កើតកិច្ចពិភាក្សាដោយផ្សារភ្ជាប់សហគមន៍ជាមួយ អង្គការដៃគូ អាជ្ញាធរតំបន់ ក្រុមជំនុំ និងក្រុមសហគមន៍ដទៃទៀត។ អង្គការទស្សនៈពិភពលោកបានរៀបចំវគ្គបណ្តុះបណ្តាលតស៊ូមតិចំនួន២០ នៅតាមកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន១៩ និងតាមគម្រោងពិសេសបី ដោយមានប្រជាជនសហគមន៍ចំនួន៦១៧ចូលរួម រួមទាំងយុវជន និងកុមារចំនួន ១១៧នាក់។

នៅខេត្តបាត់ដំបង សព្វថ្ងៃនេះ តាមសាលាមួយចំនួនមានទឹកស្អាត មានបង្គន់សម្រាប់កុមារី និងបង្គន់សម្រាប់កុមារាផ្សេងពីគ្នា ទាំងនេះបានមកពីសិស្សទាំងនោះបាននិយាយប្រាប់លោកគ្រូ អ្នកគ្រូ និងឪពុកម្តាយរបស់ពួកគេដើម្បីពង្រឹងស្ថានភាពគ្មានអនាម័យទាំងនោះ។

នៅខេត្តកណ្តាល មានក្រុមមាតាបានប្រើឥទ្ធិពលលើមណ្ឌលសុខភាពដោយធ្វើឲ្យមានបុគ្គលិកធ្វើការពេញម៉ោងតាមមណ្ឌលសុខភាព និងបន្ថែមនូវបន្ទប់ថែទាំសុខភាពសម្រាប់ស្ត្រីមានផ្ទៃពោះ និងសម្រាលកូន ដូច្នេះស្ត្រីជាច្រើនអាចទទួលបានការថែទាំសុខភាពកាន់តែប្រសើរឡើង។

នៅខេត្តកណ្តាលដដែល អាជ្ញាធរមួយចំនួនកំពុងតែបោះជំហានធ្វើការដើម្បីការពារកុមារ និងយុវជនពីការជួញដូរ និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងគ្មានសុវត្ថិភាព ពីព្រោះក្រុមកុមារ និងសហគមន៍មិនខ្លាចនិយាយពីកង្វល់របស់ពួកគេនោះទេ។

រយៈពេលមួយឆ្នាំកន្លងមក អង្គការទស្សនៈពិភពលោកបានពង្រឹងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយមន្ត្រីរដ្ឋាភិបាល អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ហើយយើងនឹងបន្តពង្រឹងកិច្ចសហការរបស់យើងទៅអនាគតបន្ថែមទៀត។

តាមរយៈការរីកចម្រើនសម្រាប់ការតស៊ូមតិ អង្គការទស្សនៈពិភពលោកនឹងធ្វើយុទ្ធនាការ ស្តីពី "ការលើកកម្ពស់សុខភាពកុមារ" នៅប្រទេសកម្ពុជាដោយចាប់ផ្តើមពីឆ្នាំ២០១២ទៅ ។ អង្គការទស្សនៈពិភពលោកនឹងចូលរួមចលនាសកលដើម្បីឆ្ពោះទៅដល់គោលដៅអភិវឌ្ឍសហសវត្សទីបួនដើម្បីកាត់បន្ថយមរណភាពកុមារអាយុក្រោមប្រាំឆ្នាំនៅកម្ពុជា ព្រោះតែការស្លាប់នោះកើតឡើងដោយសារជំងឺដែលអាចទប់ស្កាត់បាន។






"ខ្ញុំស្រលាញ់គ្រួសារខ្ញុំនិងយុវជនទាំងអស់ជាពិសេសយុវតី។ ខ្ញុំចង់ឲ្យពួកគេទាំងអស់មានសុវត្ថិភាព។ ខ្ញុំរៀនបានច្រើនជាមួយអង្គការទស្សនៈពិភពលោកពីការជួញដូរមនុស្ស។ ខ្ញុំខ្លាចអំពើជួញដូរមនុស្សណាស់ ប៉ុន្តែយើងអាចដោះស្រាយបញ្ហានេះបាន"។

"គ្រប់មេរៀនទាំងអស់ដែលខ្ញុំបានរៀននៅទីនេះ ខ្ញុំនឹងចែកចាយដល់សមាជិកគ្រួសាររបស់ខ្ញុំ បន្ទាប់មកដល់សមាជិកកុមារក្លិបទាំងអស់ និងអ្នកជិតខាង។ ខ្ញុំមានផែនការដើម្បីធ្វើការសម្តែងរឿង សម្រាប់យុទ្ធនាការនៅក្នុងសហគមន៍របស់ខ្ញុំ"។




"ខ្ញុំបង្រៀនមូលដ្ឋានគ្រឹះភាសាអង់គ្លេសដល់កុមារមួយចំនួនក្នុងភូមិរបស់ខ្ញុំដោយមិនយកប្រាក់កម្រៃ។ ខ្ញុំស្រលាញ់ពួកគេ ហើយខ្ញុំចង់ឲ្យពួកគេក្លាយជាមនុស្សល្អសម្រាប់សង្គមជាតិរបស់យើង។ ហើយខ្ញុំមានសុបិនពីរ ខ្ញុំចង់ក្លាយជាគណនេយ្យករម្នាក់នៅក្នុងធនាគារឯកជនមួយ ពីព្រោះខ្ញុំចូលចិត្តគិតលេខ។ ខ្ញុំក៏ចង់ក្លាយជាមេធាវីល្អម្នាក់ផងដែរដើម្បីរកយុត្តិធម៌ឲ្យជនក្រីក្រ"។




"យើងបានសម្រេចចិត្តថតខ្សែភាពយន្តស្តីពីការចំណាកស្រុកគ្មានសុវត្ថិភាព ពីព្រោះវាកើតឡើងក្នុងសហគមន៍របស់យើងនិងក្នុងប្រទេសជាតិទាំងមូល។ ប្រជាជនភាគច្រើនធ្វើចំណាកស្រុកទៅកាន់ប្រទេសថៃ និប្រទេសម៉ាឡេស៊ី ហើយយើងគិតថា វាគ្មានសុវត្ថិភាពពីព្រោះមានមេខ្យល់បោកប្រាស់ជាច្រើន។ យើងប្រយុទ្ធប្រឆាំង និងចង់លុបបំបាត់ការធ្វើចំណាកស្រុកគ្មានសុវត្ថិភាពក្នុងសហគមន៍"។




"ខ្ញុំប្រាថ្នាចង់ឃើញសហគមន៍របស់ខ្ញុំរស់នៅក្នុងបរិស្ថានស្អាត និងពេញដោយសន្តិភាព ហើយមានសាលារៀនគ្រប់គ្រាន់ឲ្យសិស្សទាំងអស់បានចូលសិក្សា។ ខ្ញុំក៏ចង់ឃើញការបញ្ចប់គ្រប់រូបភាពនៃអំពើហិង្សា ហើយឪពុកម្តាយគ្រប់រូបបង្ហាញពីសេចក្តីស្រលាញ់ដ៏កក់ក្តៅចំពោះកូនៗរបស់ពួកគេគ្រប់ពេលវេលា"។

# ការបង្ហាញ និងការចែកចាយនូវសេចក្តីស្រឡាញ់

"ព្រះយេស៊ូមានវ័យចម្រើនឡើង ហើយមានប្រាជ្ញាកាន់តែវាងវៃជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងជាទីគាប់ចិត្តមនុស្សផងទាំងពួង" (លូកា ២:៥២)

ក្នុងនាមជាអង្គការគ្រិស្តបរិស័ទ ដែលផ្តោតលើកុមារ ពួកយើងមានការជម្រុញចិត្តដោយសេចក្តីជំនឿដើម្បីចែកចាយនូវសេចក្តីស្រលាញ់ពី ព្រះអម្ចាស់ ព្រះយេស៊ូគ្រិស្ត និងផ្តល់អំណាចដល់សហគមន៍ ដើម្បីផ្តល់នូវមជ្ឈដ្ឋានមួយប្រកបដោយការយកចិត្តទុកដាក់ និងថែបំប៉នដល់កុមារ។




ក្នុងឆ្នាំ២០១១ គម្រោងគំនិតផ្តួចផ្តើមនៃទីបន្ទាល់របស់គ្រិស្តបរិស័ទនៃអង្គការទស្សនៈពិភពលោក បានដាក់ឱ្យប្រើប្រាស់សាកល្បងនូវឧបករណ៍ថែបំប៉នផ្នែកព្រលឹងវិញ្ញាណសម្រាប់កុមារ ដល់ការិយាល័យ៦កន្លែងនៃកម្មវិធីអភិវឌ្ឍន៍តំបន់ និងសហការជាដៃគូ ជាមួយក្រុមជំនុំ ដើម្បីរួមចំណែកដល់កិច្ចអភិវឌ្ឍន៍តំបន់សហគមន៍ក្រីក្រនៅតាមជនបទ។ តាមរយៈដៃគូទាំងនេះ ការថែបំប៉នភាវៈព្រលឹងវិញ្ញាណរបស់កុមារមានគោលបំណងលើកកម្ពស់ភាពជឿជាក់របស់កុមារ បង្កើនការចូលរួមរបស់ពួកគេ ផ្តល់ឱកាសដល់កុមារ ដើម្បីចែកចាយបទពិសោធន៍ខាងភាវៈព្រលឹងវិញ្ញាណដែលនាំគេឲ្យស្គាល់ព្រះ យល់ពីបុគ្គលិកលក្ខណៈរបស់ទ្រង់ ហើយមានទំនាក់ទំនងជាមួយព្រះអង្គ ដើម្បីឲ្យពួកគេអាចក្លាយជាស្មបន្ទាល់ពីក្តីស្រលាញ់របស់ព្រះអម្ចាស់ទៅអ្នកជិតខាង ។

អ្នកដឹកនាំយុវជនក្នុងក្រុមជំនុំ ត្រូវបានលើកទឹកចិត្តឱ្យជួយដល់កុមារតូចៗក្នុងក្លិបកុមារដោយលើកម្ពស់សមត្ថភាពការអាន និងសរសេរ កសាងសមត្ថភាពផ្នែកបំនិនជីវិត និងរៀនពីការតស៊ូមតិដើម្បីបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពានលើកុមារ។

អង្គការទស្សនៈពិភពលោក បានផ្តល់វគ្គបណ្តុះបណ្តាលលើប្រធានបទភាពជាឪពុកម្តាយល្អដល់បុគ្គលិក សមាជិកក្រុមជំនុំ ប្រជាជនសហគមន៍ចំនួន ២៩៥នាក់ និងបណ្តុះបណ្តាលដល់គ្រូបង្រៀនថ្ងៃអាទិត្យក្នុងព្រះវិហារចំនួន ១៤៨នាក់ លើប្រធានបទ ការបង្កើតបរិស្ថានទូទៅដែលកុមារអាចដឹងពីសុវត្ថិភាព និងសេចក្តីស្រឡាញ់។








# ជំនឿ និងការអត់ធ្មត់ ដើម្បីការផ្លាស់ប្រែ

សុខនឿន អាយុ២៨ឆ្នាំ បានតស៊ូបង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងចែកចាយដំណឹងល្អរបស់ព្រះអម្ចាស់នៅក្នុងព្រះវិហាររបស់គាត់។

"គ្រប់គ្នានៅក្នុងភូមិពិតជាមិនចូលចិត្តគ្រិស្តបរិស័ទទេ ហើយពួកគេមិនចង់ឲ្យមានក្រុមជំនុំណាមួយនៅក្នុងភូមិទេ។ ពួកគេហាក់បីដូចជាប្រឆាំងនឹងជំនឿគ្រិស្តបរិស័ទ ហើយព្យាយាមគំរាមកំហែងខ្ញុំតាមវិធីជាច្រើន"។

"កុមារនៅក្នុងភូមិត្រូវបានបង្គាប់ដោយមនុស្សចាស់ឲ្យចោលដុំថ្មមកដំបូលវិហារពេលខ្ញុំកំពុងថ្វាយបង្គំ។ ម្ដងនោះក្រុមក្មេងទំនើងបានមកគំរាមកំហែងខ្ញុំនៅក្នុងភូមិឲ្យឈប់ចែកចាយពីដំណឹងល្អនៅក្នុងភូមិ"។

តាមរយៈសកម្មភាពនានារបស់អង្គការទស្សនៈពិភពលោកកម្ពុជា សុខនឿន អាចបង្កើននូវការទំនាក់ទំនងរបស់គាត់ជាមួយសហគមន៍។ គាត់បានលើកទឹកចិត្តអ្នកភូមិឲ្យបើកចំហចិត្តរៀន និងបង្កើនការយល់ដឹងពីបញ្ហាដូចជា៖ មេរោគអេដស៍ និងជំងឺអេដស៍ អនាម័យខ្លួនប្រាណ និងអនាម័យបរិស្ថាន និងបានរៀបចំថ្នាក់ភាសាអង់គ្លេសឲ្យកុមារ។ ដោយសារសកម្មភាពទាំងអស់នេះ ប្រជាជននៅក្នុងភូមិស្រលាញ់ និងគោរពសុខនឿនណាស់សព្វថ្ងៃនេះ។

"ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះព្រះជាម្ចាស់ សម្រាប់ដៃគូអភិវឌ្ឍន៍ដ៏ល្អដូចជាអង្គការទស្សនៈពិភពលោកកម្ពុជាដែលមានគោលបំណងផ្ដល់ឲ្យកុមារគ្រប់រូបទទួលបានជីវិតពេញបរិបូណ៌ និងសហគមន៍រស់នៅដោយសេចក្ដីថ្លៃថ្នូរ ក្នុងព្រះនាមព្រះអម្ចាស់ព្រះយេស៊ូគ្រិស្ត"

សុខនឿន មិនដែលបោះបង់ចោលនូវជំនឿរបស់គាត់ទេ គាត់នៅតែបន្តបម្រើព្រះយេស៊ូ ដោយតែងតែចែកចាយដំណឹងល្អជាមួយអ្នករាល់គ្នា ដែលគាត់បានជួប។ សុខនឿន នៅតែមានសង្ឃឹមថាថ្ងៃណាមួយគាត់នឹងត្រូវបានគេទទួលស្គាល់នៅក្នុងភូមិរបស់គាត់។

# ជំនួយសង្គ្រោះបន្ទាន់សម្រាប់តម្រូវការបន្ទាន់

## ជម្លោះព្រំដែនបានបណ្តាលឲ្យមានប្រជាជនភៀសសឹករាប់ពាន់នាក់

នៅខែកុម្ភៈ ឆ្នាំ២០១១ ជម្លោះផ្ទុះអាវុធតាមព្រំដែនរវាងកងទ័ពកម្ពុជា និងថៃ នៅភាគខាងជើងខេត្តព្រះវិហារ បានបណ្តាលឲ្យប្រជាជនរាប់ពាន់គ្រួសារផ្លាស់ទីលំនៅ។ អង្គការទស្សនៈពិភពលោក បានជួយសង្គ្រោះប្រជាពលរដ្ឋចំនួន២.០០០គ្រួសារ ព្រមទាំងកុមារងាយរងគ្រោះផងដែរ ដើម្បីកាត់បន្ថយហានិភ័យផ្នែកសុខភាព និងដើម្បីធានាឲ្យបាននូវលក្ខខណ្ឌរស់នៅប្រកបដោយសុវត្ថិភាព។

អង្គការទស្សនៈពិភពលោក បានធ្វើការផ្តល់នូវបង្គន់យ៉ាងសមរម្យនៅក្នុងជំរុំភៀសសឹក ផ្តល់ទឹកស្អាត សំពត់តង់សម្រាប់ធ្វើជម្រក និងផ្សព្វផ្សាយការយល់ដឹងស្តីពីការអនុវត្តអនាម័យខ្លួនប្រាណ និងអនាម័យជាមូលដ្ឋាន។

ដោយឡែកដើម្បីការពារ និងសុខុមាលភាពកុមារ អង្គការទស្សនៈពិភពលោកបានរៀបចំកន្លែងកុមាររីករាយ ដើម្បីផ្តល់នូវកន្លែងសុវត្ថិភាពដល់កុមារលេង និងជួយពួកគេមានលំនឹងផ្នែកសតិអារម្មណ៍។



ដើម្បីថែទាំកុមារពេលមានគ្រោះទឹកជំនន់ភ្លាមៗ កន្លែងកុមាររីករាយត្រូវបានរៀបចំឡើងនៅក្នុងស្រុកបី ដែលមានកុមារភៀសខ្លួនចំនួន៥០២នាក់ មានកន្លែងសុវត្ថិភាពលេងកំសាន្ត រៀនពីបំនិនជីវិត របៀបការពារខ្លួន និងរៀនពីរបៀបថែរក្សាសុខភាព និងព្រលឹងវិញ្ញាណឲ្យបានល្អផងដែរ។

## ប្រទេសកម្ពុជាទទួលរងគ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរដែលមិនធ្លាប់មានចាប់តាំងពីឆ្នាំ២០០០

នៅចុងខែកញ្ញាឆ្នាំ២០១១ ភ្លៀងនៅតែបន្តធ្លាក់យ៉ាងខ្លាំង ដែលបណ្តាលឲ្យមានគ្រោះមហន្តរាយទឹកជំនន់ដ៏ធ្ងន់ធ្ងរនៅក្នុង ១៦ខេត្តក្នុងចំណោម ២៤ខេត្តក្រុងរបស់ប្រទេសកម្ពុជា ដែលធ្វើឲ្យប៉ះពាល់ដល់ប្រជាជនជាងមួយលាននាក់ ដូចជាផ្ទះសម្បែង សាលារៀន ស្រែចំការត្រូវបានទទួលរងការខូចខាត និងបំផ្លាញទាំងស្រុង។ អង្គការទស្សនៈពិភពលោកជាអង្គការមួយឆ្លើយតបដល់ក្រុមគ្រួសារ ដែលទទួលរងប៉ះពាល់ដោយគ្រោះទឹកជំនន់មុនគេ និងបម្រើទៅនឹងសេចក្តីត្រូវការបន្ទាន់របស់គ្រួសារចំនួន ១០.៥៧១ ក្នុងខេត្តទាំង៨។

ជាមួយនឹងក្តីបារម្ភសុខភាពដែលកើតមានដោយសារទឹកជំនន់កខ្វក់ និងជំងឺដែលអាចបណ្តាលមកពីទឹក បុគ្គលិកចុះតាមមូលដ្ឋានរបស់អង្គការទស្សនៈពិភពលោក បានសម្របសម្រួលជាមួយមន្ទីរសុខាភិបាលខេត្ត ការិយាល័យសុខាភិបាលស្រុក និងមណ្ឌលសុខភាពដើម្បីផ្តល់នូវវគ្គបណ្តុះបណ្តាលពីអនាម័យខ្លួនប្រាណ និងអនាម័យទូទៅដល់ជនភៀសខ្លួនទាំងនោះ។

អង្គការទស្សនៈពិភពលោកនឹងបន្តឧបត្ថម្ភដល់សហគមន៍ដែលរងប៉ះពាល់ដោយគ្រោះទឹកជំនន់ ដើម្បីស្តារឡើងវិញនូវវិស័យកសិកម្ម ធ្វើឲ្យប្រសើរឡើងផ្នែកផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងបន្តជួយសហគមន៍កាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយធម្មជាតិនានានៅពេលអនាគត។

## ការចែកជំនួយគ្រោះទឹកជំនន់

### អនាម័យ និងទឹកស្អាត

- ក្រណាត់ច្រោះទឹក ចំនួន ១.៣៤០ដុំ
- ធុងទឹក និងធុងចម្រោះទឹកចំនួន ៦៤៤ធុង
- ផលិតផលបន្សុទ្ធទឹក ៩៩.៤៣៥ កញ្ចប់
- ម្សៅសាប៊ូចំនួន ៩៣២គីឡូក្រាម
- ថ្នាំក្លរចំនួន ១.០៣២ គ្រាប់
- សាប៊ូដុសខ្លួនចំនួន ១២.០៣៥ ដុំ

### អាហារ

- ទឹកស៊ីអ៊ីវ និងទឹកត្រីចំនួន ៥.៧៧៩ ដប
- ចែកអង្ករចំនួន ១៧៦.៨៩៣ គីឡូក្រាម
- ត្រីខកំប៉ុងចំនួន ១៤.១១១ កំប៉ុង
- អំបិលអ៊ីយ៉ូដចំនួន ១.៨២៥ គីឡូក្រាម

### ជម្រក និងសំលៀកបំពាក់

- ការ៉ុងប្រចកដីខ្សាច់ ៣៣គីឡូក្រាម
- ការ៉ុងចំនួន២៧៧
- សារ៉ុងចំនួន៣៦២
- ក្រម៉ាចំនួន៩៩២
- ពិលចំនួន៦០
- តង់ចំនួន១.០៤៧
- មុងចំនួន១.៤៤២
- ភួយចំនួន៩៦៥
- កន្ទេលចំនួន៦០




# កន្លែងដែលមានសុវត្ថិភាពសម្រាប់ស្រីនោ

បន្ទាប់ពីមានភ្លៀងធ្លាក់ខ្លាំងស្ទើរពេញមួយខែមក បានធ្វើឲ្យមានគ្រោះទឹកជំនន់ដ៏ធំនៅក្នុងភូមិរបស់នាងក្នុងស្រុកកោះអណ្តែត ខេត្តតាកែវ ទឹកជំនន់មិនទាន់បានស្រកចេញពីផ្ទះស្រីនោដែលមានអាយុ ១០ឆ្នាំជាកុមារទំនុកបម្រុង នាងរស់នៅជាមួយឪពុកម្តាយ និងប្អូនស្រីរបស់នាង។

នាងនិយាយថា "ពេលមានទឹកជំនន់ធំកើតឡើង ខ្ញុំខ្លាចលង់ទឹក ពស់ចឹក និងខ្យល់បក់ខ្លាំងៗ"។

នៅចុងខែតុលា អង្គការទស្សនៈពិភពលោកកម្ពុជា បានរៀបចំកន្លែងកុមាររីករាយនៅក្នុងភូមិរបស់ស្រីនោ ដែលមានចំងាយមិនឆ្ងាយពីផ្ទះរបស់នាង។

ក្នុងកន្លែងកុមាររីករាយ កុមារនៅក្នុងភូមិស្រីនោអាចច្រៀងចម្រៀង លេងល្បែងកំសាន្ត អានសៀវភៅ និងរៀនពីមេរៀនសំខាន់ស្តីពីមូលដ្ឋានគ្រឹះអនាម័យខ្លួនប្រាណ និងអនាម័យបរិស្ថាន។ កុមារក៏សិក្សាពីរបៀបយល់ដឹងនៃបរិស្ថានរបស់ពួកគេ និងពីរបៀបការពារខ្លួនរបស់ពួកគេពីគ្រោះថ្នាក់ផ្សេងៗ។

គ្រួសាររបស់ស្រីណូ ក៏បានទទួលជំនួយសង្គ្រោះបន្ទាន់ពីអង្គការទស្សនៈពិភពលោក ដែលពិតជាសំខាន់ណាស់ព្រោះវាចំពេលដែលអាហាររបស់ពួកគេបានថយចុះ។




"ពេលបុគ្គលិកអង្គការទស្សនៈពិភពលោកកម្ពុជាមកដល់ និងបានរៀបចំកន្លែងកុមាររីករាយនៅក្នុងភូមិរបស់ខ្ញុំ មិត្តខ្ញុំ និងខ្ញុំអាចលេង និងរៀនដូចយើងនៅក្នុងសាលារៀនម្តងទៀតអញ្ចឹង"

# នៅតែបន្តផ្តល់ជូនសេវាបម្រើអ្នកដែលមិនទាន់បានទទួលសេវាគ្រប់គ្រាន់

ថ្វីបើស្ថានភាពហិរញ្ញវត្ថុពិភពលោកធ្លាក់ចុះអស់រយៈពេលជាច្រើនឆ្នាំកន្លងមកក៏ដោយ វិស័យមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា មានការលូតលាស់យ៉ាងខ្លាំង និងរឹងមាំ ក្នុងនោះរួមមានវីសិនហ្វាន់ផងដែរ។ ជាមួយនឹងភាពជោគជ័យនេះ វិស័យនេះក៏ប្រឈមនឹងការប៉ុនប៉ងទាក់ទាញអតិថិជនក្នុងចំនួនច្រើនឲ្យប្រើប្រាស់ឥណទានខ្នាតធំដែលអាចកាត់បន្ថយចំណាយរដ្ឋបាល និងធ្វើឲ្យប្រសើរឡើងដល់ស្ថានភាពហិរញ្ញវត្ថុក្នុងស្ថាប័នមីក្រូហិរញ្ញវត្ថុ។

ជាលទ្ធផល ប្រជាជនក្រីក្រមួយចំនួន ដែលមានប្រាក់ចំណូលទាប ហើយដែលត្រូវការប្រាក់កម្ចីជាចាំបាច់នោះត្រូវបានគេមើលរំលង។

ដូច្នេះ នៅក្នុងឆ្នាំ២០១១ វីសិនហ្វាន់ដែលជាស្ថាប័នមីក្រូហិរញ្ញវត្ថុដ៏ធំមួយនៅក្នុងប្រទេសកម្ពុជាបានចាប់យកនិន្នាការ និងបន្តប្តេជ្ញាបម្រើអតិថិជនដែលមានប្រាក់ចំណូលទាប និងអ្នកដែលមិនទាន់ទទួលសេវាគ្រប់គ្រាន់ដទៃទៀត តាមរយៈការផ្តល់ប្រាក់កម្ចីធ្វើអាជីវកម្មខ្នាតតូចដែលមានទឹកប្រាក់ជាមធ្យមតិចជាង ២៩០ដុល្លារសហរដ្ឋអាមេរិក (កម្ចីជាមធ្យមនៅក្នុងទីផ្សារមានទំហំធំជាង៥០០ដុល្លារសហរដ្ឋអាមេរិក)។ វីសិនហ្វាន់មិនជឿថា ខ្លួនត្រូវជ្រើសរើសរវាងការបម្រើប្រជាជនក្រីក្រ និងនិរន្តរភាពរបស់ស្ថានប័នខ្លួននោះទេ។

វីសិនហ្វាន់ជឿជាក់ថាជម្រើសទាំងពីរនេះ ខ្លួនអាចសម្រេចបានក្នុងពេលតំណាលគ្នា។

តាមរយៈការគ្រប់គ្រងចំណាយយ៉ាងហ្មត់ចត់ និងពង្រឹងប្រសិទ្ធភាពការងារ នៅដំណាច់ឆ្នាំ២០១១ វិសិនហ្វាន់មិនត្រឹមតែអាចបង្កើនចំនួនអតិថិជនពី ១០៨.០០០នាក់ក្នុងឆ្នាំ២០១០ ដល់ចំនួន១៣២.០០០នាក់ រួមមានកុមារ៩៦.០០០នាក់ដែលបានទទួលផលប៉ះពាល់ជាវិជ្ជមាន វិសិនហ្វាន់ក៏អាចធ្វើឲ្យប្រសើរឡើងនូវស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួនទាំងមូល ខណៈពេលដែលអត្រាចំណាយប្រតិបត្តិការត្រូវបានកាត់បន្ថយ ។

VisionFund
CAMBODIA

| ២០១០ (មិនទាន់ធ្វើសវនកម្ម) | វិសិនហ្វាន់ (កម្ពុជា) | ២០១១ (មិនទាន់ធ្វើសវនកម្ម) |
|---|---|---|
| ១០៨.០៤៧ | ចំនួនអ្នកខ្ចីសកម្ម | ១៣២.០៣៦ |
| ៨៨% | %អ្នកខ្ចីជាស្ត្រី | ៩២% |
| ១១ | ចំនួនខេត្តប្រតិបត្តិការ | ១១ |
| ១០០ | ចំនួនស្រុកប្រតិបត្តិការ | ១០៨ |
| ៦២៧ | បុគ្គលិកសរុប | ៧០០ |
| $៣០.០១៧.០៤៤ | ផលប័ត្រឥណទាន | $៣៧.៧១៩.០៨៦ |
| $២៧៨ | ផលប័ត្រឥណទានជាមធ្យមសម្រាប់អ្នកខ្ចីម្នាក់ | $២៨៦ |
| $៦៩.២០៨ | ផលប័ត្រឥណទានជាមធ្យមសម្រាប់មន្ត្រីឥណទានម្នាក់ | $១០៩.៣៣១ |
| 0.៥០% | ផលប័ត្រឥណទានមានហានិភ័យ > ៣០ថ្ងៃ | 0.១៤% |
| $៣៦.៦២៧.០២៨ | សរុបទ្រព្យសកម្ម | $៤៤.២៤០.៩៧៥ |
| $៩.២៦៤.៧៣០ | សរុបមូលនិធិម្ចាស់ហ៊ុន | $១២.២៧០.៧៧៦ |
| ១១១% | និរន្តរភាពប្រតិបត្តិការ | ១១៩% |
| ១០៥% | និរន្តរភាពហិរញ្ញវត្ថុ | ១១២% |
| ២.៨០% | ចំណូលធៀបទ្រព្យសកម្ម | ៤.២៣% |






# ភិន ហេន ធ្វើការតាមរបៀបរបស់គាត់

"ប្រសិនបើគ្មានវិសិហ្វាន់នោះទេ ខ្ញុំប្រហែលជាក្លាយកម្មករអស់មួយជីវិតហើយមើលទៅ"

"កូនៗរបស់ខ្ញុំអាចទៅសាលារៀនបាន ហើយជីវិតរបស់យើងគឺពិតជាផ្លាស់ប្តូរ។ សុបិនរបស់ខ្ញុំបានក្លាយជាការពិត"។

ភិន ហេន អាយុ៣៨ឆ្នាំ មកពីស្រុកលើកដែក ខេត្តកណ្តាល បានទទួលប្រាក់កម្ចីជា ច្រើនពីវិសិនហ្វាន់ ដែលបានជួយគាត់កសាងជីវិតដ៏ប្រសើរមួយសម្រាប់កូនប្រុសទាំងពីររបស់គាត់។ ហេន បានប្រើប្រាស់ប្រាក់កម្ចីដើម្បីទិញជីសម្រាប់ដាក់ស្រែចំការរបស់គាត់ ទិញសាំងសម្រាប់ម៉ាស៊ីនធ្វើស្រែចំការ ទិញដីមួយកន្លែង គោមួយនឹម ទិញម៉ាស៊ីនភ្លើង ម៉ាស៊ីនកិនពោត ម៉ាស៊ីនបូមទឹក និងសម្ភារជាច្រើនផ្សេងទៀតដើម្បីធ្វើឲ្យអាជីវកម្មរីកចម្រើនឡើង។

គាត់និយាយថា "បុគ្គលិករបស់វិសិនហ្វាន់បានបង្រៀនខ្ញុំពីការគ្រប់គ្រង និងការប្រើប្រាស់លុយឲ្យមានប្រសិទ្ធភាព និងត្រូវគោលដៅ"។

សព្វថ្ងៃនេះប្រាក់ចំណូលរបស់ហេនមានការប្រសើរឡើង ហើយសមាជិកគ្រួសាររបស់គាត់មានសុខភាពល្អ និងកូនៗរបស់គាត់អាចទៅសាលារៀនបានហើយមានសម្ភារសិក្សាគ្រប់គ្រាន់។

ហេន និយាយថា "គោដែលខ្ញុំបានទិញមានកូនពីរហើយ។ ខ្ញុំបានលក់មួយ។ ខ្ញុំអាចរកប្រាក់បានពីម៉ាស៊ីនចំនួន១០០.០០០រៀល (២៥ដុល្លារសហរដ្ឋអាមេរិក) ក្នុងមួយខែៗ"។ គាត់ក៏បានរកប្រាក់ចំណូលបន្ថែមទៀតពីម៉ាស៊ីនកិនពោតផងដែរ។ "ខ្ញុំបានទិញម៉ាស៊ីនកិនពោតពីរបីខែមុន ហើយខ្ញុំរកលុយបានពីម៉ាស៊ីនកិនពោតចំនួន ២.៤០០.០០០រៀល (៦០០ដុល្លារសហរដ្ឋអាមេរិក)"។

ពីមុន ហេន បានធ្វើការនៅលើដីស្រែចំការមានទំហំតូច ហើយក៏បានធ្វើការជាកម្មករនៅដីស្រែប្រជាជនផ្សេងទៀត។ ប្តីរបស់គាត់ក៏រកប្រាក់ចំណូលជាអ្នកជីកអណ្តូង។ ថ្វីបើគាត់ខិតខំប្រឹងប្រែងធ្វើការយ៉ាងណាក៏ដោយ ក៏ប្រាក់ចំណូលរបស់ពួកគេមិនគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ក្រុមគ្រួសារដែរ។

ហេន ទទួលស្គាល់ថា "ខ្ញុំធ្លាប់ចង់បញ្ឈប់កូនរបស់ខ្ញុំឲ្យឈប់រៀនដើម្បីជួយខ្ញុំធ្វើស្រែចំការ" ហេនចែកចាយទៀតថា "ខ្ញុំមិនមានលុយទិញថ្នាំពេទ្យ ឬបញ្ជូនកូនៗរបស់ខ្ញុំទៅមន្ទីរពេទ្យទេ ពេលពួកគេឈឺ។ កូនៗរបស់ខ្ញុំឈឺពីព្រោះគ្មានអាហារគ្រប់គ្រាន់ទទួលទាន"។

ហេន និយាយថា"ពេលខ្លះខ្ញុំគ្មានសង្ឃឹមទេ។ ខ្ញុំពិតជាបារម្ភពីអនាគតកូនៗខ្ញុំ ពីព្រោះខ្ញុំគ្មានលុយគ្រប់គ្រាន់ផ្គត់ផ្គង់ពួកគេឲ្យទៅសាលារៀនទេ"។

## ការចំណាយសាច់ប្រាក់នៅឆ្នាំសារពើពន្ធ ២០១១ តាមប្រទេសផ្តល់ជំនួយ




## ចំណាយសាច់ប្រាក់តាមប្រភេទជំនួយ



កម្មវិធីទំនុកបម្រុង
$១៣.៩៨១.៧៧៨
៧៥%

ឯកជន មិនមែនតាមកម្មវិធីទំនុកបម្រុង
$៣.៣១២.៩៥៧
១៨%

រដ្ឋាភិបាល
$១.៤៤៩.៥៤១
៨%

## ប្រភេទនៃការចំណាយតាមគម្រោងក្នុងឆ្នាំសារពើពន្ធ២០១១

**ចំណាយតាមគម្រោងផ្ទាល់**
**$១៦,៧៨៩,០៤៧**
**៩០%**



**ចំណាយតាមគម្រោងមិនផ្ទាល់**
**$១,៩៥៥,២២៩**
**១០%**

សាច់ប្រាក់ទាំងអស់ខាងលើគិតជាដុល្លារអាមេរិក

## ចំណាយលើគម្រោងផ្ទាល់តាមផ្នែក

| | | |
|---|---|---|
| $២.១១៦.៧៧៣ | ១៣% | ផ្នែកកុមារស្ថិតក្នុងវិបត្តិ និងការការពារ |
| $២.៣៣៨.៧៨៧ | ១៤% | ផ្នែកការគ្រប់គ្រងកម្មវិធីទំនុកបម្រុង |
| $២.៥៨៩.៨៧៨ | ១៥% | ផ្នែកសង្គមស៊ីវិល និងការតស៊ូមតិ |
| $៣.៦២៧.៨០២ | ២២% | ផ្នែកសុខភាពអាហារូបត្ថម្ភ អេដស៍ និងអនាម័យទឹកស្អាត |
| $១.១៦២.៦៤៩ | ៧% | ផ្នែកសន្តិសុខស្បៀង និងកសិកម្ម |
| $១.០២១.៣១៥ | ៦% | ផ្នែកអប់រំ |
| $២៥៦.១៣៣ | ២% | ផ្នែកកាត់បន្ថយគ្រោះមហន្តរាយ និងឆ្លើយតបសង្គ្រោះបន្ទាន់ |
| $៤៤៨.៨៣៩ | ៣% | ផ្នែកតាមដាន និងវាយតម្លៃ និងវាយតម្លៃ/ចងក្រង |
| $២៣៣.៥៩០ | ១% | ផ្នែកព័ន្ធកិច្ចគ្រីស្តបរិស័ទ |
| $២.៧៧៥.១០៧ | ១៦% | ផ្នែកគ្រប់គ្រងកម្មវិធី និងគម្រោង |
| $២១៨.១៧៣ | ១% | ផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ |

## អាហារ និងអំណោយផ្សេងៗ

បន្ថែមលើសាច់ប្រាក់ យើងបានទទួល និងចែកចាយអាហារ និងអំណោយផ្សេងៗដូចជា៖ អាហារបានមកពីអង្គការស្បៀងអាហារពិភពលោកដែលមានតម្លៃជាទឹកប្រាក់ចំនួន៧០៩.៦៩៣ដុល្លារសហរដ្ឋអាមរិក។សម្ភារមិនមែនជាអាហារមានតម្លៃជាទឹកប្រាក់ចំនួន៩៥.៣៣២ដុល្លារសហរដ្ឋអាមេរិក រួមមានស្បែកជើងឃ្លុបចំនួន១.៤៥៤គូ និងស្បែកជើងផ្ទាត់កុមារចំនួន ៤.៨០១គូ។

**រចនាក្រាហ្វិក និងកាច់ទំព័រដោយ**
រចនាឌីហ្សាញ www.rachnadesign.com info@rachnadesign.com

**អត្ថបទ និងរូបថតដោយ**
ក្រុមទំនាក់ទំនងព័ត៌មាន និងសារព័ត៌មាន, ភ្នំពេញ
ក្រុមសម្របសម្រួលទីផ្សារ និងរកមូលនិធិរបស់វីសិនហ្វាន់កម្ពុជា

**បោះពុម្ពផ្សាយនៅកម្ពុជាក្នុងឆ្នាំ ២០១២**
ផ្នែកនៃព័ត៌មាននេះអាចនឹងបោះពុម្ពផ្សាយបន្ត ប្រសិនបើមានការអនុញ្ញាត។ របាយការណ៍នេះអាចរកបានពីអង្គការទស្សនៈពិភពលោកកម្ពុជា។



World Vision


**អង្គការទស្សនៈពិភពលោកកម្ពុជា**

អាគារលេខ២០ ផ្លូវលេខ៧១
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
ប្រអប់សំបុត្រ លេខ៤៧៩
ភ្នំពេញ–កម្ពុជា
ទូរស័ព្ទ: +៨៥៥–២៣–២១៦ ០៥២
ទូរសារ: +៨៥៥–២៣–២១៦ ២២០

អ៊ីម៉ែល: cambodia@wvi.org
www.worldvision.org.kh